ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលការណ៍ប្រតិបត្តិស្តង់ដា
## ស្តីពី
# ការលើកកម្ពស់សុខភាពសិក្សា
## សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ




នាយកដ្ឋានសុខភាពសិក្សា
ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ប្រតិបត្តិស្តង់ដា

## ស្តីពី

# ការលើកកម្ពស់សុខភាពសិក្សា

## សម្រាប់ គ្រឹះស្ថានសិក្សាចំណេះទូទៅ

នាយកដ្ឋានសុខភាពសិក្សា

ឆ្នាំ២០២២





**សុខភាពគ្រូនិងសិស្ស ជាសុខភាពសិក្សា!**

# បុព្វកថា

ក្នុងបរិបទឧស្សាហកម្ម ៤.០ ពិភពលោកបានឈានដល់ដំណាក់កាលថ្មីមួយកាន់តែបើកចំហ ដែលនាំមកនូវការប្រកួតប្រជែងកាន់តែស្រួចស្រាល់ និងវិស័យបច្ចេកវិទ្យានិងវិទ្យាសាស្ត្រកាន់តែទំនើប។ ប្រការនេះតម្រូវឱ្យមានការអភិវឌ្ឍធនធានមនុស្សប្រកបដោយសក្ដានុពលទាំងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា។ សុខភាពនិងសុវត្ថិភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំជាកត្តាគន្លឹះ ដើម្បីសម្រេចបំណងប្រាថ្នាខាងលើ ។

អង្គការសុខភាពពិភពលោក (WHO) និងអង្គការសហប្រជាជាតិសម្រាប់អប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) បានផ្ដួចផ្ដើមបង្កើតឯកសារ "ស្តង់ដាសកលស្ដីពីការលើកកម្ពស់សុខភាពតាមគ្រឹះស្ថានសិក្សា" ដើម្បីជាមគ្គុទ្ទេសក៍សម្រាប់អនុវត្តចាប់ពីថ្នាក់ជាតិរហូតដល់គ្រឹះស្ថានសិក្សា។ ការលើកកម្ពស់សុខភាពតាមគ្រឹះស្ថានសិក្សាមានឥទ្ធិពលជាវិជ្ជមានទៅលើសុខភាពរបស់កុមារ យុវវ័យ និងជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតរស់នៅប្រកបដោយសុខភាពល្អ និងជាផ្នែកមួយយ៉ាងសំខាន់ក្នុងការពង្រឹង និងលើកកម្ពស់សមត្ថភាពការសិក្សា ការរស់នៅ និងការធ្វើកិច្ចការប្រចាំថ្ងៃទាំងពេលបច្ចុប្បន្ន និងអនាគត។

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍ **"គោលការណ៍ប្រតិបត្តិស្តង់ដាស្ដីពីការលើកកម្ពស់សុខភាពសិក្សា សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ"** ក្នុងគោលបំណងជំរុញការអនុវត្តកម្មវិធីសុខភាពសិក្សាគ្រប់ជ្រុងជ្រោយ នៅតាមគ្រឹះស្ថានសិក្សាស្របតាមគោលនយោបាយជាតិស្ដីពីសុខភាពសិក្សា ជាពិសេសដើម្បីជាមគ្គុទ្ទេសក៍សម្រាប់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សានិងអ្នកពាក់ព័ន្ធ សិក្សាស្វែងយល់ និងយកទៅអនុវត្តជាជំហានៗប្រកបដោយភាពច្នៃប្រឌិត ដើម្បីប្រែក្លាយជា "គ្រឹះស្ថានសិក្សាលើកកម្ពស់សុខភាព"។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា **"គោលការណ៍ប្រតិបត្តិស្តង់ដាស្ដីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ"**នេះ ក្លាយជាឯកសារមួយសម្រាប់ជាជំនួយស្មារតីដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមអភិវឌ្ឍគ្រឹះស្ថានសិក្សាឱ្យក្លាយជាកន្លែងប្រកបដោយសុខភាព សុវត្ថិភាព និងផាសុកភាពសម្រាប់អ្នកសិក្សានិងបុគ្គលិកអប់រំ។

ថ្ងៃសុក្រ ១០កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណចំពោះ

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាគ្រប់លំដាប់ថ្នាក់ ដែលបានគាំទ្រនិងផ្តល់អនុសាសន៍ល្អៗក្នុងការអភិវឌ្ឍឯកសារ **"គោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ"** និងអនុញ្ញាតឱ្យបោះពុម្ពប្រើប្រាស់ជាផ្លូវការ។

អង្គការសុខភាពពិភពលោក ដែលបានចូលរួមគាំទ្រទាំងថវិកា បច្ចេកទេស និងបានផ្តួចផ្តើមផ្តល់ឯកសារយោងពាក់ព័ន្ធ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំតាក់តែងឯកសារនេះឱ្យមានលក្ខណៈគ្របដណ្តប់គ្រប់ជ្រុងជ្រោយសម្រាប់អនុវត្តនៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅនៅកម្ពុជា។

ក្រុមការងារបច្ចេកទេសមកពីក្រសួងអប់រំ យុវជន និងកីឡា ក្រោមការដឹកនាំរបស់នាយកដ្ឋានសុខភាពសិក្សា ដោយមានការចូលរួមពីនាយកដ្ឋានអប់រំកុមារតូច នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានផែនការ មកពីក្រសួងសុខាភិបាល រួមមានមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព នាយកដ្ឋានការពារសុខភាព នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ បាណកសាស្ត្រ អង្គការ FIDR អង្គការ GIZ មូលនិធិប្រេហ្វតហូឡូប្រចាំកម្ពុជា អង្គការ Save The Children Cambodia អង្គការ UNICEF អង្គការ UNFPA អង្គការ WFP និងអ្នកពាក់ព័ន្ធដទៃទៀតដែលបានចូលរួមចំណែកចែករំលែកនូវចំណេះដឹង បទពិសោធន៍ល្អៗ និងបានផ្តល់ជំនួយបច្ចេកទេសក្នុងការអភិវឌ្ឍខ្លឹមសារគោលការណ៍ប្រតិបត្តិនេះឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ អនុលោមតាមឯកសាររបស់អង្គការសុខភាពពិភពលោក និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលបានបោះពុម្ពផ្សាយនាពេលកន្លងមក ដោយផ្សារភ្ជាប់ទៅនឹងបរិបទនៃប្រទេសកម្ពុជា។

# សន្ទានុក្រម

- **កម្មវិធីសិក្សា** សំដៅដល់សំណុំមុខវិជ្ជាដែលត្រូវបានរៀបចំឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ចំណេះធ្វើ សីលធម៌ និងសមត្ថភាពបន្តការសិក្សាពេញមួយជីវិត។
- **កម្មវិធីសិក្សាលម្អិត** សំដៅដល់ឯកសារកម្មវិធីសិក្សាដែលមានខ្លឹមសារចែងពីលទ្ធផលរំពឹងទុក របាយម៉ោង ការណែនាំអនុវត្ត ការវាយតម្លៃ និងវិធីសាស្ត្របង្រៀន ដើម្បីកំណត់បានថាពេលរៀនចប់មេរៀននីមួយៗ អ្នកសិក្សាទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ស្របតាមគោលបំណងនៃមេរៀន។
- **ការអប់រំសុខភាព** សំដៅដល់សកម្មភាពនិងមធ្យោបាយនានា ក្នុងការណែនាំមនុស្សឱ្យចេះបង្ការពីជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈផ្សេងទៀត។
- **ការលើកកម្ពស់សុខភាពតាមគ្រឹះស្ថានសិក្សា** សំដៅដល់សកម្មភាពដែលគ្រឹះស្ថានសិក្សាពង្រឹងខ្លួនឯងប្រកបដោយនិរន្តរភាពលើផ្នែកសុវត្ថិភាព សុខភាព ដល់អ្នកសិក្សា និងបុគ្គលិកអប់រំ ឬជាសកម្មភាពគ្រឹះស្ថានសិក្សាដែលបានអនុវត្តតាម សូចនាករនៃគោលការប្រតិបត្តិស្ដីពីការលើកកម្ពស់សុខភាព។
- **ក្របខណ្ឌកម្មវិធីសិក្សា** សំដៅដល់ឯកសារផែនការដែលកំណត់សំណុំស្តង់ដាសិក្សាសម្រាប់កម្មវិធីសិក្សានៃភូមិសិក្សានានា ព្រមទាំងផ្តល់នូវបរិបទក្នុងការកំណត់មាតិកាមុខវិជ្ជាដែលសិស្សត្រូវរៀន វិធីរៀន និងវិធីបង្រៀន ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ព្រមទាំងប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សាផងដែរ។
- **បរិយាបន្ន** សំដៅដល់ការរួមបញ្ចូលគ្នានៃការផ្តល់សេវា ការប្រើប្រាស់សេវានានានៅតាមគ្រឹះស្ថានសិក្សាសម្រាប់មនុស្សគ្រប់រូបដោយមិនគិតពីពិការភាព ឋានៈ យេនឌ័រ ពណ៌សម្បុរ សាសនា ជាតិសាសន៍ ស្ថានភាព និងជីវភាពគ្រួសារ។
- **បំណិន** សំដៅដល់ភាពប៉ិនប្រសប់ និងសមត្ថភាពដែលទទួលបានតាមរយៈកិច្ចខិតខំប្រឹងប្រែងដោយចេតនាជាប្រព័ន្ធ និងប្រកបដោយចីរភាព ពាក់ព័ន្ធនឹងគំនិត (បំណិនមនោគិត) វត្ថុ (បំណិនបច្ចេកទេស) អាចរួមបញ្ចូលទាំងមនុស្ស (មានភាពប៉ិនប្រសប់ខាងទំនាក់ទំនង)។

- **បង្គន់នោម** សំដៅដល់ឧបករណ៍សម្រាប់មនុស្សប្រុសនោមដែលគេបំពាក់ភ្ជាប់ជាមួយទីតាំងអគារ បន្ទប់ទឹក ឬបង្គន់អនាម័យ។
- **សុខភាពសិក្សា** សំដៅដល់សំណុំសកម្មភាពផ្សេងៗសម្រាប់លើកកម្ពស់សុខភាពនៅតាមគ្រឹះស្ថានសិក្សាដែលជាសេចក្តីត្រូវការជាមូលដ្ឋាននៃផ្លូវកាយ ផ្លូវចិត្ត និងសង្គមរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ។
- **ឯកជនភាព** សំដៅដល់ស្ថានភាពដែលគ្មានការរំខានឬការសង្កេតមើលឃើញរឿងឯកជនពីអ្នកដទៃ។

# គណៈកម្មការដឹកនាំគ្រប់គ្រង

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រី

ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ

លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការ

# គណៈកម្មការនិពន្ធ

លោក **គឹម សាញ់**

លោក **នេត្រ តារម្យ**

លោកស្រី **ឌី សុមាលី**

លោកស្រី **ឯកទិត្យ ធីតា**

កញ្ញា **ហ៊ុន សោភ័ណ**

លោកស្រី **ហ៊ុន ហ្សីឌីឡា**

លោក **សួន ពិលាភ**

លោកស្រី **សរ ហ៊ីន**

លោក **លី លាងសេង**

លោកស្រី **ស្លាត ចិន្តា**

លោកស្រី **ពេជ សុគន្ធា**

លោកស្រី **ភាន់ សុធារី**

លោក **ម៉ាន់ ថាវរិទ្ធ**

# គណៈកម្មការរៀបរៀងនិងត្រួតពិនិត្យបច្ចេកទេស

លោកជំទាវបណ្ឌិត **សឿ សុជាតា**

លោកជំទាវវេជ្ជបណ្ឌិត **ឆាយគឹម សុទ្ធាវី**

ឯកឧត្តមវេជ្ជបណ្ឌិត **យង់ គន្ធារិទ្ធ**

លោកជំទាវវេជ្ជបណ្ឌិត **សូ ឆវីរត្ន**

# ការីកុំព្យូទ័រ

លោក **សួន ពិលាភ**

លោក **ភុត ខូន**

# អារម្ភកថា

សុខភាពសិក្សានៅកម្ពុជាមានការវិវត្តប្រែប្រួលពីសម័យកាលមួយទៅសម័យកាលមួយឥតឈប់ឈរ ដោយផ្ដើមចេញជាដំបូងផ្ដោតលើអនាម័យសិក្សារបស់អ្នកសិក្សា និងបុគ្គលិកអប់រំ ពិសេសសេវាពិនិត្យនិងថែទាំសុខភាព។ ជាការកត់សម្គាល់ការងារសុខភាពសិក្សាបានវិវត្តយ៉ាងលឿននៅជិតមួយទស្សវត្សរ៍ចុងក្រោយក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈបង្កើតឱ្យមានជាគោលនយោបាយជាតិស្ដីពីសុខភាពសិក្សា ព្រមទាំងមានយន្តការចូលរួមពីគ្រប់វិស័យពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

នៅក្នុងដំណើរវិវត្តនៃការងារសុខភាពសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តកម្មវិធីជាច្រើនមានដូចជា មុខវិជ្ជាអប់រំសុខភាពដាច់ដោយឡែក រយៈពេល១ម៉ោងក្នុង១សប្ដាហ៍ពីថ្នាក់ទី១ដល់ទី១២ គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមាស្ដីពីទឹកស្អាតនិងអនាម័យនៅតាមគ្រឹះស្ថានសិក្សា គោលការណ៍ណែនាំស្ដីពីការវាស់គំហើញនៅតាមគ្រឹះស្ថានសិក្សា សេវាសង្គ្រោះបឋម បន្ទប់សុខភាព ការពិនិត្យសុខភាពនិងកាយសម្បទា គោលការណ៍ណែនាំស្ដីពីសុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភនិងចំណីអាហារប្រកបដោយសុខភាពនៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅ គោលការណ៍ប្រតិបត្តិស្ដីពីការសង្គ្រោះសុខភាពផ្លូវចិត្តបឋមនៅតាមគ្រឹះស្ថានសិក្សា ព្រមទាំងគោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាព ក្នុងបរិបទនៃជំងឺកូវីដ-១៩ ជាដើម។

ទន្ទឹមនឹងនេះ ដោយសារគ្រឹះស្ថានសិក្សានីមួយៗមានស្ថានភាពខុសៗគ្នាទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ធនធានមនុស្ស និងមធ្យោបាយគាំទ្រផ្សេងៗ ធ្វើឱ្យការអនុវត្តសកម្មភាពជាក់ស្ដែងនៃការងារសុខភាពសិក្សា នៅកម្រិតគ្រឹះស្ថានសិក្សាមានភាពមិនដូចគ្នាឡើយ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ នាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសុខភាពពិភពលោក និងដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងស្ថាប័នជាតិ អន្តរជាតិទ្វេភាគី ពហុភាគី និងសង្គមស៊ីវិល បានផ្តួចផ្ដើមអភិវឌ្ឍ **"គោលការណែនាំប្រតិបត្តិស្តង់ដាស្ដីពីការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅ"**នេះឡើង។ នៅក្នុងការរៀបចំឯកសារនេះ គណៈកម្មការ

តាក់តែង បានបន្សុីគ្នារវាងកម្មវិធីសុខភាពសិក្សាដែលមានស្រាប់ ជាមួយនឹងឧត្តមានុវត្ត នៃការអនុវត្តជាក់ស្តែងនៅតាមគ្រឹះស្ថានសិក្សាផ្ទាល់និងអនុសាសន៍របស់អង្គការសុខភាព ពិភពលោក។

"**គោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ**"នេះ ជាសមិទ្ធិផលថ្មីមួយទៀតដែលរួមចំណែកយ៉ាងសំខាន់ក្នុង ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ។ ឯកសារនេះ ត្រូវបានរៀបចំដោយ ពន្យល់បង្ហាញពីស្តង់ដា សូចនាករសម្រាប់ស្វ័យវាយតម្លៃពីស្ថានភាពអនុវត្តគោលការណ៍ ប្រតិបត្តិក្នុងការបំពេញសូចនាករ និងមានរូបភាពបញ្ជាក់សម្រាប់អនុវត្តកម្មវិធីនីមួយៗ ជំហានសម្រាប់អនុវត្តនៃការលើកកម្ពស់សុខភាពសិក្សា ព្រមទាំងឧបសម្ព័ន្ធចាំបាច់នានា ដែលអាចជាជំនួយស្មារតីដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ និងអ្នក ពាក់ព័ន្ធដទៃទៀត ដើម្បីយកទៅអនុវត្តប្រកបដោយគំនិតច្នៃប្រឌិត ភាពបត់បែន ស្រប តាមធនធាន និងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានគ្រឹះស្ថានសិក្សានីមួយៗ ក្នុងគោល បំណងបង្កើតបាននូវគុណតម្លៃនៃ **"ការលើកកម្ពស់សុខភាពតាមគ្រឹះស្ថានសិក្សា"** ពិត ប្រាកដជាក់ស្តែង។

គណៈកម្មការយើងខ្ញុំសង្ឃឹមថា ឯកសារនេះនឹងបានជាប្រយោជន៍ដ៏សំខាន់សម្រាប់ អ្នកអនុវត្ត ជាពិសេសគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ដៃគូអភិវឌ្ឍ សហគមន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមវិភាគទាន ក្នុងការលើកកម្ពស់សុខភាពតាមគ្រឹះស្ថានសិក្សាជាជំហានៗនៅកម្ពុជាប្រកបដោយគុណ ភាពនិងប្រសិទ្ធភាព។

**គណៈកម្មការនិពន្ធ**

# មាតិកា

ទំព័រ


**បុព្វកថា** ....................................................................................iii

**សេចក្តីថ្លែងអំណរគុណ** .................................................................... iv

**សន្ទានុក្រម** ................................................................................v

**អារម្ភកថា**..................................................................................viii

**មាតិកា** ......................................................................................x

**១- សេចក្តីផ្តើម** ..........................................................................1

**២- គោលដៅ** .................................................................................3

**៣- ក្រុមគោលដៅប្រើប្រាស់** ..............................................................4

**៤- ស្តង់ដាការលើកកម្ពស់សុខភាពសិក្សា** ...............................................5

**៥- សេចក្តីណែនាំប្រតិបត្តិសម្រាប់សូចនាករស្តង់ដានីមួយៗ** ..........................7

**សូចនាករស្តង់ដាទី១**- គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា ...........7

**សូចនាករស្តង់ដាទី២**- ក្រុមប្រតិបត្តិស្តីពីសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា..... 10

**សូចនាករស្តង់ដាទី៣**- បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា ............................ 12

**សូចនាករស្តង់ដាទី៤**- សេវាពិនិត្យសុខភាពដល់អ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សា.. 13

**សូចនាករស្តង់ដាទី៥**- ការផ្តល់ថ្នាំបង្ការដល់អ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សា ........ 16

**សូចនាករស្តង់ដាទី៦**- បណ្តាញទឹកស្អាតសម្រាប់ទទួលទានប្រចាំថ្ងៃ .................... 18

**សូចនាករស្តង់ដាទី៧**- ការអនុវត្តយន្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព................................................. 19

**សូចនាករស្តង់ដាទី៨**- សួនបន្លែនិងសួនជីវៈចម្រុះដើម្បីជំរុញការយល់ដឹងពីអាហារូបត្ថម្ភដែលមានលក្ខណៈចម្រុះ............................................ 21

**សូចនាករស្តង់ដាទី៩**- បណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ.......................22

**សូចនាករស្តង់ដាទី១០**- បរិក្ខារលាងសម្អាតដៃដោយមានទឹកស្អាតនិងសាប៊ូសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ....................................................23

**សូចនាករស្តង់ដាទី១១**- បង្គន់អនាម័យ បង្គន់នោមសមស្របតាមតម្រូវការប្រើប្រាស់ប្រកបដោយបរិយាបន្ន ឯកជនភាព សុវត្ថិភាព និងរក្សាភាពស្អាតជាប់ជាប្រចាំ...................................................25

**សូចនាករស្តង់ដាទី១២**- ការទុកដាក់សំណល់ ការបែងចែកសំរាមត្រឹមត្រូវស្របតាមលក្ខណៈបច្ចេកទេស ....................................................27
**សូចនាករស្តង់ដាទី១៣**- អនាម័យបរិស្ថានគ្រឹះស្ថានសិក្សាស្អាតនិងមានសុវត្ថិភាព ..28
**សូចនាករស្តង់ដាទី១៤**- សួនស្មៅ សួនផ្កា ដើមរុក្ខជាតិសម្រាប់លម្អ និងដើមឈើយកម្លប់29
**សូចនាករស្តង់ដាទី១៥**- ទីលានអនុវត្តអប់រំកាយនិងកីឡាសមស្រប .....................31
**សូចនាករស្តង់ដាទី១៦**- ទីធ្លា កន្លែងអង្គុយលេង ឬសម្រាកកម្សាន្តសមស្រប .........32
**សូចនាករស្តង់ដាទី១៧**- ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅតាមគ្រឹះស្ថានសិក្សា....33
**សូចនាករស្តង់ដាទី១៨**- ឧបករណ៍សម្រាប់បង្ការ ការពារ និងអន្តរាគមន៍ពេលមានគ្រោះអាសន្ននៅតាមអគារសិក្សា .................................34
**សូចនាករស្តង់ដាទី១៩**- ផែនការបង្រៀននិងកាលវិភាគបង្រៀនមុខវិជ្ជាអប់រំសុខភាពទៅតាមកម្មវិធីលម្អិត និងប្រធានបទសុខភាពសាធារណៈដទៃទៀតតាមការចាំបាច់...........................................36
**សូចនាករស្តង់ដាទី២០**- សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព និងសម្ភារៈអប់រំផ្សព្វផ្សាយដទៃទៀត ..................................................38
**សូចនាករស្តង់ដាទី២១**- គ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាព....................................40
**សូចនាករស្តង់ដាទី២២**- ការអនុវត្តអនាម័យផ្ទាល់ខ្លួន .........................................41
**សូចនាករស្តង់ដាទី២៣**- ការអនុវត្តបំណិនសង្គ្រោះបឋម...................................42
**សូចនាករស្តង់ដាទី២៤**- ការអនុវត្តវិធានការបង្ការជំងឺផ្សេងៗ..............................44
**សូចនាករស្តង់ដាទី២៥**- លំហាត់ប្រាណនិងសកម្មភាពរាងកាយ (គួរបញ្ចូលគ្នាជាមួយសូចនាករទីធ្លាហាត់ប្រាណ) .......................................46
**សូចនាករស្តង់ដាទី២៦**- យន្តការកៀរគរប្រភពធនធាននិងការគាំទ្រពីដៃគូពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពសិក្សា...............................47

**៦- សូចនាករស្វ័យវាយតម្លៃការលើកកម្ពស់សុខភាពសិក្សា**............. 48

**៧- ឧបសម្ព័ន្ធ** ..................................................................................... 55

៧.១- ឧបសម្ព័ន្ធ១: អំពីបន្ទប់សុខភាព .....................................................55

៧.២- ឧបសម្ព័ន្ធ២: ឯកសារចាំបាច់សម្រាប់ប្រើប្រាស់នៅបន្ទប់សុខភាព....................... 71

៧.៣- ឧបសម្ព័ន្ធ៣:  អ្នកពាក់ព័ន្ធសម្រាប់ទាក់ទងបន្ទាន់ ..........................................78

**៨- ឯកសារយោង** .................................................................. 79

## ១- សេចក្ដីផ្ដើម

ការលើកកម្ពស់សុខភាពសិក្សា ជាការងារអាទិភាពមួយដែលចូលរួមសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ស្ដីពីការអប់រំនៅកម្ពុជា "គុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា ឧត្ដមសិក្សា ការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ និងការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ ស្របតាមយុគសម័យបច្ចេកទេស ឌីជីថល ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខុដុមជីវិតបុគ្គល និងសង្គម"។ បុគ្គលិកអប់រំនិងអ្នកសិក្សាមានសុខភាពល្អ នឹងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៀននិងបង្រៀន ជាពិសេសជួយបង្កើនអត្រាគង់វង្ស និងបង្កើនភាពវៃឆ្លាតរបស់អ្នកសិក្សា។ ផ្ទុយទៅវិញ បើសុខភាពមានបញ្ហានឹងក្លាយជាឧបសគ្គចម្បងមួយរារាំងការទទួលបាននូវការសិក្សាល្អប្រសើរនៅក្នុងអំឡុងពេលសិក្សា ប្រការនេះបានបង្ហាញកាន់តែច្បាស់ក្នុងអំឡុងពេលការរាតត្បាតសកលនៃជំងឺកូវីដ-១៩។

ការអនុវត្តកម្មវិធីសុខភាពសិក្សានៅកម្ពុជាមានការវិវត្តជាជំហានៗ ស្របទៅនឹងយុទ្ធសាស្ត្រ ចតុកោណជំណាក់កាលទី៤ នៅមុំទី១ស្ដីពីការអភិវឌ្ឍធនធានមនុស្ស និងមុំទី៣ស្ដីពីការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ ក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព បង្កើនផលិតភាពការងារខ្ពស់ សុខភាពរឹងមាំ និងកំណើនសេដ្ឋកិច្ច ឆ្ពោះទៅសម្រេចចក្ខុវិស័យប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការលើកកម្ពស់សុខភាពសិក្សាដោយបានដាក់ចេញនូវគោលនយោបាយជាតិស្ដីពីសុខភាពសិក្សា សំណុំយុទ្ធសាស្ត្រ និងសកម្មភាពអន្តរកម្មរវាងគ្រឹះស្ថានសិក្សា និងសេវាកម្មសុខភាពនានា តាមរយៈការផ្ដល់សេវាអប់រំសុខភាព ការបង្ការជំងឺ ការបង្កើតបន្ទប់សុខភាព សេវាពិនិត្យសុខភាពនិងកាយសម្បទា សេវាសង្គ្រោះបឋម សេវាអាហារូបត្ថម្ភ សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាព សេវាលើកកម្ពស់ អនាម័យ បរិស្ថាន និងការផ្គត់ផ្គង់ទឹកស្អាតជាដើម។

ទោះបីមានគោលនយោបាយ គោលការណ៍ណែនាំ និងកម្មវិធីអន្តរាគមន៍ខាងលើនេះក៏ដោយ ក៏ការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាមិនទាន់បានអនុវត្តគ្រប់ជ្រុងជ្រោយពេញលេញស្របទៅនឹងសេចក្ដីត្រូវការនៅឡើយ។ ឆ្លើយតបនឹងបញ្ហា

ខាងលើនេះ នាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសុខភាពពិភពលោក បានផ្តួចផ្តើមបង្កើត **“គោលការណ៍ណែនាំប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅ”** នេះឡើង។ ឯកសារថ្មីនេះស្របគ្នានឹងគោលការណ៍ “ស្តង់ដាសកលស្តីពីការលើកកម្ពស់សុខភាពតាមគ្រឹះស្ថានសិក្សា” ដែលបានអនុម័តដោយអង្គការសុខភាពពិភពលោកនិងអង្គការយូនីស្វូ ដែលបានអនុម័តកាលពីពាក់កណ្តាលឆ្នាំ២០២១ ដើម្បីជាមគ្គុទេសក៍សម្រាប់អនុវត្តទាំងកម្រិតជាតិរហូតដល់គ្រឹះស្ថានសិក្សា។

## ២- គោលដៅ

គោលដៅសំខាន់នៃឯកសារនេះគឺ សម្រាប់គាំទ្រដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាចំណេះទូទៅនិងគ្រូបង្រៀនគ្រប់កម្រិតថ្នាក់ ដើម្បីចូលរួមរៀបចំអនុវត្ត **"ការលើកកម្ពស់សុខភាពសិក្សា"** ស្របតាមបរិបទថ្មីនៃការវិវត្តផ្នែកសុខភាពសាធារណៈសំដៅធានាដល់សុខភាព សុវត្ថិភាព និងផាសុកភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំនៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន។

ឯកសារ **"គោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ"** នេះ បានរំលេចនូវសូចនាករស្តង់ដាដែលត្រូវអនុវត្តអនុលោមតាមយុទ្ធសាស្ត្រនីមួយៗនៃគោលនយោបាយជាតិស្តីពីសុខភាពសិក្សា ផ្សារភ្ជាប់ជាមួយគោលការណ៍ប្រតិបត្តិស្តង់ដា ដែលបានពីបទពិសោធន៍ជាក់ស្តែងនៃការអនុវត្តសកម្មភាពនានានៅតាមគ្រឹះស្ថានសិក្សានាពេលកន្លងមក។ បន្ថែមលើសពីនេះ មានឧបសម្ព័ន្ធមួយចំនួនសម្រាប់ផ្ទៀងផ្ទាត់ ត្រួតពិនិត្យការអនុវត្តជាក់ស្តែងប្រចាំថ្ងៃ ដើម្បីធានាថាគ្រឹះស្ថានសិក្សាអាចដំណើរការប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សគ្រប់រូប ដោយមិនប្រកាន់ភេទ អាយុ ពិការភាព ឋានៈគ្រួសារ ព្រមទាំងអ្នកងាយរងគ្រោះនោះទេ។

លើសពីនេះ ក្រុមការងារបច្ចេកទេសបានបញ្ចូលនូវសកម្មភាពសម្រាប់ជាការអនុវត្តប្រចាំថ្ងៃ ដែលបានដកស្រង់ចេញពីអនុសាសន៍របស់អង្គការសុខភាពពិភពលោក (WHO) និងអង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) ស្តីពីការរៀបចំគ្រឹះស្ថានសិក្សាឱ្យក្លាយជាទីកន្លែងលើកកម្ពស់សុខភាពសិក្សា ដែលបានចេញផ្សាយកាលខែមិថុនា ឆ្នាំ២០២១ ព្រមទាំងសម្រង់ខ្លឹមសារសំខាន់ៗមួយចំនួននៃគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទកូវីដ-១៩" ផងដែរ។



## ៣- ក្រុមគោលដៅប្រើប្រាស់

ឯកសារ **"គោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ"** នេះនឹងក្លាយជាឧបករណ៍ជំនួយស្មារតីថ្មីមួយសម្រាប់គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូនៅតាមគ្រឹះស្ថានសិក្សាដែលមានបំណងចង់រៀបចំគ្រឹះស្ថានសិក្សារបស់ខ្លួន ស្របតាមបរិបទថ្មីនៃការវិវត្តផ្នែកសុខភាពសាធារណៈសំដៅធានាដល់សុខភាព សុវត្ថិភាព និងផាសុកភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំ។

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលទទួលខុសត្រូវក្នុងការអភិវឌ្ឍគ្រឹះស្ថានសិក្សា អាចរៀបចំការងារ **"លើកកម្ពស់សុខភាពតាមគ្រឹះស្ថានសិក្សា"** ជាជំហានៗតាមសមត្ថភាព ធនធានដែលមាន និងអាចរកបានដោយមានភាពទន់ភ្លន់បត់បែនតាមស្ថានភាពជាក់ស្តែងរបស់គ្រឹះស្ថានសិក្សានីមួយៗ។ ផ្តើមចេញពីការវាយតម្លៃលើស្ថានភាពគ្រឹះស្ថានសិក្សា ដោយធ្វើការផ្ទៀងផ្ទាត់នូវសូចនាករដែលមាន ឬអាចបំពេញបាន គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធផ្សេងទៀតអាចពិភាក្សាគ្នារិះរកមធ្យោបាយ ដើម្បីរៀបចំផែនការមេអភិវឌ្ឍគ្រឹះស្ថានសិក្សារបស់ខ្លួន ចាប់ផ្តើមពីកែលម្អស្ថានភាពសូចនាករដែលមិនទាន់មាន ពិសេសផ្តើមចេញពីចំណុចតូចៗដែលអាចធ្វើបានជាមុន។ ធ្វើបែបនេះ វាជាជំហានលើកទឹកចិត្តខ្លួនឯងក្នុងការបន្តជំហានទៅមុខទៀត តាមផែនការគ្រោងទុករហូតដល់អាចបំពេញបាននូវសូចនាករស្តង់ដាសំខាន់ៗដែលជាផ្នែកមិនអាចខ្វះបាន ដើម្បីប្រែក្លាយទៅជា **"គ្រឹះស្ថានសិក្សាអនុវត្តការលើកកម្ពស់សុខភាពស្តង់ដា"**។

## ៤- ស្តង់ដាការលើកកម្ពស់សុខភាពសិក្សា

អនុលោមតាមយុទ្ធសាស្ត្រទាំង៩នៃគោលនយោបាយជាតិស្តីពីសុខភាពសិក្សា គោលការណ៍ណែនាំប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សា ត្រូវបានរៀបចំដូចខាងក្រោម៖

| ល.រ | ស្តង់ដា | សូចនាករស្តង់ដាការលើកកម្ពស់សុខភាពសិក្សា |
|---|---|---|
| ១ | ការអភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ | ១- គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា |
| | | ២- ក្រមប្រតិបត្តិស្តីពីសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា |
| ២ | ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សានិងបុគ្គលិកអប់រំ | ៣- បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា |
| | | ៤- សេវាពិនិត្យសុខភាពដល់អ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សា |
| | | ៥- ការផ្តល់ថ្នាំបង្ការដល់អ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សា |
| ៣ | ការលើកកម្ពស់ការផ្តល់អាហារូបត្ថម្ភ | ៦- បណ្តាញទឹកស្អាតសម្រាប់ទទួលទានប្រចាំថ្ងៃ |
| | | ៧- ការអនុវត្តយន្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព |
| | | ៨- សួនបន្លែនិងសួនជីវៈចម្រុះដើម្បីជំរុញការយល់ដឹងពីអាហារូបត្ថម្ភដែលមានលក្ខណៈចម្រុះ |
| ៤ | ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ | ៩- បណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ |
| | | ១០- បរិក្ខារលាងសម្អាតដៃដោយមានទឹកស្អាតនិងសាប៊ូសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ |
| | | ១១- បង្គន់អនាម័យ បង្គន់នោមសមស្របតាមតម្រូវការប្រើប្រាស់ប្រកបដោយបរិយាបន្ន ឯកជនភាព សុវត្ថិភាព និងរក្សាភាពស្អាតជាប់ជាប្រចាំ |
| | | ១២- ការទុកដាក់និងគ្រប់គ្រងកាកសំណល់ ការបែងចែកសំរាមត្រឹមត្រូវស្របតាមលក្ខណៈបច្ចេកទេស |

| ល.រ | ស្តង់ដា | សូចនាករស្តង់ដាការលើកកម្ពស់សុខភាពសិក្សា |
|---|---|---|
| ៥ | ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្នផាសុកភាព និងមេត្រីភាព | ១៣- អនាម័យបរិស្ថានគ្រឹះស្ថានសិក្សាស្អាតនិងមានសុវត្ថិភាព |
| | | ១៤- សួនស្មៅ សួនផ្កា ដើមរុក្ខជាតិសម្រាប់លម្អ និងដើមឈើយកម្លប់ |
| | | ១៥- ទីលានសម្រាប់អនុវត្តអប់រំកាយនិងកីឡាសមស្រប |
| | | ១៦- ទីធ្លា កន្លែងអង្គុយលេង ឬសម្រាកកម្សាន្តសមស្រប |
| ៦ | ការលើកកម្ពស់សន្តិសុខនិងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា | ១៧- ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅតាមគ្រឹះស្ថានសិក្សា |
| | | ១៨- ឧបករណ៍សម្រាប់បង្ការ ការពារ និងអន្តរាគមន៍គ្រោះអាសន្ននៅតាមអគារសិក្សា |
| ៧ | ការលើកកម្ពស់ការអប់រំសុខភាព | ១៩- ផែនការបង្រៀននិងកាលវិភាគបង្រៀនមុខវិជ្ជាអប់រំសុខភាពទៅតាមកម្មវិធីលម្អិត និងប្រធានបទសុខភាពសាធារណៈដទៃទៀតតាមការចាំបាច់ |
| | | ២០- សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព និងសម្ភារៈអប់រំផ្សព្វផ្សាយដទៃទៀត |
| | | ២១- គ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាព |
| ៨ | ការលើកកម្ពស់ការអនុវត្តបំណិនសុខភាព | ២២- ការអនុវត្តអនាម័យផ្ទាល់ខ្លួន |
| | | ២៣- ការអនុវត្តបំណិនសង្គ្រោះបឋម |
| | | ២៤- ការអនុវត្តវិធានការបង្ការជំងឺផ្សេងៗ |
| | | ២៥- ការហាត់ប្រាណនិងសកម្មភាពរាងកាយ |
| ៩ | ការលើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍកម្មវិធីសុខភាពសិក្សា | ២៦- យន្តការកៀរគរប្រភពធនធាននិងការគាំទ្រពីដៃគូពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពសិក្សា |

## ៥- សេចក្តីណែនាំប្រតិបត្តិសម្រាប់សូចនាករស្តង់ដានីមួយៗ

ខាងក្រោមនេះជាការបរិយាយលម្អិតស្តីពីគោលការណ៍ប្រតិបត្តិនៃការអនុវត្តការលើកកម្ពស់សុខភាពតាមគ្រឹះស្ថានសិក្សា ទៅតាមសូចនាករស្តង់ដានីមួយៗនៃការលើកកម្ពស់សុខភាពសិក្សា៖

### សូចនាករស្តង់ដាទី១- គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា

គណៈកម្មការសុខភាពសិក្សា គឺជាយន្តការមួយសម្រាប់សម្របសម្រួលដឹកនាំការងារសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា ដើម្បីធានាសុខភាព សុវត្ថិភាព និងសុខុមាលភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំ។

គណៈកម្មការសុខភាពសិក្សា បង្កើតឡើងដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន បុព្វជិតសាសនា សហគមន៍ និងអ្នកអាណាព្យាបាលជាដើម។ គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាត្រូវបង្កើតឡើងចេញពីគំនិតផ្តួចផ្តើមរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាមី តាមរយៈកិច្ចប្រជុំពិភាក្សាជាមួយភាគីពាក់ព័ន្ធដូចជា មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក អាជ្ញាធរដែនដី ក្រុមប្រឹក្សាឃុំ សង្កាត់ វត្តអារាម វិហារសាសនា សប្បុរសជន មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីទទួលការគាំទ្រនិងកំណត់លើសមាសភាពនិងតួនាទីនិងភារកិច្ចដែលត្រូវធ្វើ។

គណៈកម្មការសុខភាពសិក្សារួមមាន ប្រធាន០១រូបនិងអនុប្រធានតាមការចាំបាច់ ព្រមទាំងសមាជិកមួយចំនួនអាស្រ័យលើទំហំការងារនិងតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសិក្សាសាមី។ គណៈកម្មការសុខភាពសិក្សា ត្រូវមាននីត្យានុកូលត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច។

ខាងក្រោមនេះជាឧទាហរណ៍នៃសមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការសុខភាពសិក្សាតាមគ្រឹះស្ថានសិក្សា៖

### គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា

**ក- សមាសភាព៖**

| | |
|---|---|
| ១- អភិបាល/អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ឬមេឃុំ ចៅសង្កាត់គោលដៅ | ប្រធានកិត្តិយស |
| ២- នាយក/នាយិកាគ្រឹះស្ថានសិក្សា | ប្រធាន |

៣- នាយក/នាយិការងទទួលការងារសុខភាពសិក្សា អនុប្រធានប្រចាំការ
៤- ប្រធានឬអនុប្រធានមណ្ឌលសុខភាព ក្នុងមូលដ្ឋាន អនុប្រធាន
៥- អាជ្ញាធរមូលដ្ឋាន (សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ មេភូមិ មេប៉ុស្ត៍) សមាជិក
៦- តំណាងគ្រូពេទ្យ ឬមន្ត្រីទទួលបន្ទុកបន្ទប់សុខភាព សមាជិក
៧- តំណាងអ្នកអាណាព្យាបាល សមាជិក
៨- តំណាងស្ថាប័នសាសនា សមាជិក
៩- តំណាងសហគមន៍ ឬដៃគូពាក់ព័ន្ធ សមាជិក
១០- តំណាងអ្នកសិក្សា សមាជិក

**ខ- តួនាទី ភារកិច្ច**

- រៀបចំផែនការសកម្មភាពលើកកម្ពស់សុវត្ថិភាពនិងសុខភាពសិក្សា ដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់គ្រឹះស្ថានសិក្សា
- សហការជំរុញអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ គោលការណ៍ណែនាំពាក់ព័ន្ធនឹងការងារសុខភាពសិក្សា ដែលដាក់ចេញដោយរាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាឬក្រសួងសុខាភិបាល
- សហការអន្តរាគមន៍ និងដាក់ចេញនូវវិធានការចាំបាច់នានាសំដៅចូលរួមទប់ស្កាត់ការពារអាយុជីវិត សុវត្ថិភាព សុខភាព និងសន្តិសុខរបស់អ្នកសិក្សានិងបុគ្គលិកអប់រំពីការបង្ការជំងឺរាតត្បាត ឬជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតឱ្យបានខ្ជាប់ខ្ជួនស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល ឬ ក្រសួងអប់រំ យុវជន និងកីឡា
- សម្របសម្រួលបង្កើតឱ្យមាន **"បន្ទប់សុខភាព"** និងមាន **"អ្នកទទួលបន្ទុក"** ដោយបំពាក់នូវសម្ភារៈរូបវន្តចាំបាច់មួយចំនួន ពិសេសសម្ភារៈបង្កាទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩និងសង្គ្រោះបឋមព្រមទាំងតាមដានការប្រើប្រាស់
- សម្របសម្រួលផ្តល់សេវាត្រួតពិនិត្យសុខភាពនិងកាយសម្បទាដល់អ្នកសិក្សា និងបុគ្គលិកអប់រំ ដោយកំណត់ពេលវេលាជាក់លាក់នៅដើមឆ្នាំសិក្សានីមួយៗ ឬតាមការចាំបាច់
- សម្របសម្រួលផ្តល់ថ្នាំបង្ការ (វ៉ាក់សាំង) និងថ្នាំព្យាបាល ដល់អ្នកសិក្សាតាមគោលនយោបាយ ឬកម្មវិធីជាតិនៃការផ្តល់ថ្នាំបង្ការរបស់ក្រសួងសុខាភិបាល
- សហការអន្តរាគមន៍ផ្តល់សេវាសង្គ្រោះបន្ទាន់ឬបញ្ជូនអ្នករងគ្រោះដែលជាអ្នកសិក្សា ឬបុគ្គលិកអប់រំ ទៅមូលដ្ឋានសុខាភិបាលដែលនៅជិតគ្រឹះស្ថានសិក្សា

- សហការផ្តល់សេវាអប់រំសុខភាពសម្រាប់បង្ការជំងឺឆ្លង ជំងឺមិនឆ្លង ការបង្ការគ្រោះថ្នាក់ផ្សេងៗ និងបញ្ហាសុខភាពសាធារណៈដទៃទៀតដល់អ្នកសិក្សានិងបុគ្គលិកអប់រំ
- ផ្សព្វផ្សាយព័ត៌មាន ឯកសារពាក់ព័ន្ធនឹងការងារសុខភាពសិក្សា ដល់អ្នកសិក្សា និងបុគ្គលិកអប់រំ នៅក្នុងគ្រឹះស្ថានសិក្សា
- សម្របសម្រួលតាមដាន ការប្រើប្រាស់ ទឹកស្អាត បង្គន់អនាម័យ បង្គន់នោម និងកន្លែងលាងសម្អាតដៃ ព្រមទាំងការថែទាំ និងជួសជុលសម្ភារៈរូបវន្តអនាម័យ ការគ្រប់គ្រងសំរាម និងកាកសំណល់ផ្សេងៗ
- សហការពិនិត្យតាមដានការលក់ដូរនិងការផ្គត់ផ្គង់ចំណីអាហារ សំដៅធានាបាននូវអនាម័យ សុវត្ថិភាព និងអាហារប្រកបដោយសុខភាព នៅតាមគ្រឹះស្ថានសិក្សា
- ជូនដំណឹងដល់អ្នកពាក់ព័ន្ធ និងពិចារណាស្នើសុំ “**ផ្អាក ឬបិទ**” គ្រឹះស្ថានសិក្សាបណ្តោះអាសន្នក្នុងករណីមានជំងឺឆ្លងរាតត្បាត ឬករណីមានប្រធានសក្តិ ដើម្បីលើកវិធានការអន្តរាគមន៍ទាន់ពេលវេលា
- កៀរគរប្រភពធនធានសម្រាប់អនុវត្តការងារលើកកម្ពស់សុខភាពសិក្សានៅគ្រឹះស្ថានសិក្សា
- សហការតាមដាន វាយតម្លៃ និងចងក្រងទិន្នន័យ ស្ថិតិ និងសូចនាករពាក់ព័ន្ធនឹងការអនុវត្តការងារលើកកម្ពស់សុខភាពសិក្សា



*កិច្ចប្រជុំរបស់គណៈកម្មការសុខភាពសិក្សា សាលាបឋមសិក្សាចតុមុខ*

- ផ្តល់កិច្ចសហការក្នុងការការពារកុមារនិងយុវជន
- ធ្វើរបាយការណ៍វឌ្ឍនភាពការងារលើកកម្ពស់សុខភាពសិក្សា ជូនអ្នកពាក់ព័ន្ធតាមឋានានុក្រម។

**កំណត់សម្គាល់:** *សមាសភាព តួនាទី ភារកិច្ចរបស់គណៈកម្មការសុខភាពសិក្សាខាងលើនេះអាចបន្ថែម ឬកែសម្រួលតាមស្ថានភាពនិងតម្រូវការជាក់ស្តែងនៃគ្រឹះស្ថានសិក្សានីមួយៗ។*

## សូចនាករស្តង់ដារទី២- ក្រមប្រតិបត្តិស្តីពីសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា

គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថាននីមួយៗត្រូវបង្កើត **«ក្រមប្រតិបត្តិស្តីពីសុខភាពសិក្សា»** សម្រាប់ដាក់ឱ្យអនុវត្តចំពោះមនុស្សគ្រប់រូបដែលបំពេញការងារនៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនស្របតាមគោលបំណង គោលដៅ។ ក្រមប្រតិបត្តិនេះអាចបិទផ្សាយនៅក្នុងបរិវេណគ្រឹះស្ថានសិក្សា ដើម្បីឱ្យអ្នកសិក្សា បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធនានា ពេលចូលដល់គ្រឹះស្ថានសិក្សាត្រូវអនុវត្តតាមក្នុងគោលដៅជានាឱ្យបាននូវសុវត្ថិភាព របៀបរៀបរយ មានបរិស្ថានល្អ អនាម័យស្អាត បរិយាកាសល្អ មេត្រីភាព ផាសុកភាព។ ការគោរពនិងអនុវត្តតាមក្រមប្រតិបត្តិស្តីពីសុខភាពសិក្សា ដោយយោងតាមការណែនាំរបស់ក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា គឺជាការជួយខ្លួនឯងឱ្យមានសុវត្ថិភាព សេចក្តីថ្លៃថ្នូរ ក៏ដូចជាចូលរួមចំណែកក្នុងការលើកតម្លៃនៃគ្រឹះស្ថានសិក្សាផងដែរ។

ខាងក្រោមនេះជាឧទាហរណ៍នៃក្រមប្រតិបត្តិសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា ដែលមនុស្សទាំងអស់ត្រូវគោរពប្រតិបត្តិ៖

**ក- ប្រការដែលត្រូវហាមឃាត់**

- ហាមប្រើអំពើហិង្សាគ្រប់ប្រភេទ និងរើសអើងគ្រប់ទម្រង់
- ហាមប្រើប្រាស់សម្តីអសុរោះ
- ហាមដុតជង់ប្លាស្ទិក ឬដុតសំរាមក្នុងបរិវេណ និងជុំវិញគ្រឹះស្ថានសិក្សា
- ហាមជក់បារី
- ហាមប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- ហាមប្រើប្រាស់គ្រឿងស្រវឹងគ្រប់ប្រភេទ




- ហាមចោលសំរាមនិងកាកសំណល់ផ្សេងៗ ពាសវាលពាសកាល
- ហាមបើកបរយានជំនិះគ្រប់ប្រភេទឬស៊ីផ្លេក្នុងបរិវេណគ្រឹះស្ថានសិក្សាជាដើម។

**ខ- ប្រការដែលត្រូវអនុវត្ត**

- បរិភោគតែចំណីអាហារដែលមានសុវត្ថិភាពនិងអាហារសុខភាព
- លក់ដូរតែចំណីអាហារប្រកបដោយគុណភាពនិងសុខភាព
- បន្ទោរបង់ក្នុងបង្គន់អនាម័យឱ្យបានត្រឹមត្រូវ

- សម្អាតបង្គន់អនាម័យឱ្យបានស្អាតជានិច្ច
- បោះចោលសំរាម ក្នុងធុងដែលបានកំណត់
- លាងសម្អាតដៃនឹងសាប៊ូ មុននឹងចាប់កាន់ចំណីអាហារបរិភោគ និងបន្ទាប់ពីចេញពីបង្គន់
- ចូលរួមថែទាំឧបករណ៍ បរិក្ខារ ប្រើប្រាស់ផ្សេងៗ ជាពិសេសបរិក្ខារលាងសម្អាតដៃ និងបង្គន់អនាម័យ។

***CaQ Rb ណែនាំ*** *ខ្លឹមសារនៃក្រមប្រតិបត្តិនេះអាចមានការប្រែប្រួល បត់បែន ទន់ភ្លន់ និងមានលក្ខណៈម៉ឺងម៉ាត់ ដោយគ្រឹះស្ថានសិក្សានីមួយៗអាចបន្ថែមនិងកែសម្រួលបញ្ញត្តិខ្លឹមសារស្របតាមកាលៈទេសៈជាក់ស្តែងរបស់គ្រឹះស្ថានសិក្សានីមួយៗ។*



## សូចនាករស្តង់ដារទី៣- បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា

បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា ជាកន្លែងសម្រាប់អ្នកសិក្សានិងបុគ្គលិកអប់រំមកទទួលសេវាថែទាំសុខភាពបឋម ដោយមានមុខងារជួយសម្រួលឬសង្គ្រោះបឋមនូវបញ្ហាសុខភាព កាត់បន្ថយការឈឺចាប់ ដែលបានកើតឡើងនៅក្នុងគ្រឹះស្ថានសិក្សាមុនឈានទៅរកសេវាពិនិត្យព្យាបាលនៅតាមមន្ទីរពេទ្យឬមណ្ឌលសុខភាព។ បន្ទប់សុខភាពក៏ជាកន្លែងផ្តល់ប្រឹក្សាសុខភាពផ្លូវកាយ ផ្លូវចិត្ត សុខភាពបន្តពូជនិងសុខភាពផ្លូវភេទផងដែរ។ បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សាត្រូវមានគណៈកម្មការគ្រប់គ្រង ដឹកនាំ មានទីតាំងបន្ទប់នៅជាន់ផ្ទាល់ដី មានសម្ភារៈបម្រើការងាររដ្ឋបាល សម្ភារៈអប់រំសុខភាព និងសម្ភារៈសង្គ្រោះបឋមចាំបាច់ដទៃទៀតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។






ចំពោះបញ្ជីសម្ភារៈប្រើប្រាស់ក្នុងបន្ទប់សុខភាព បញ្ជីសម្ភារៈសម្រាប់សង្គ្រោះបឋម ដំណើរការប្រើប្រាស់ គ្រប់គ្រង និងឧបករណ៍សម្រាប់មន្ត្រីទទួលបន្ទុកបន្ទប់សុខភាពប្រើប្រាស់ប្រចាំថ្ងៃមានចែងលម្អិតក្នុង ***ឧបសម្ព័ន្ធ១*** នៃឯកសារនេះ។ ដោយឡែកចំពោះឯកសារចាំបាច់នានាសម្រាប់ប្រើប្រាស់នៅក្នុងបន្ទប់សុខភាព មានលម្អិតក្នុង ***ឧបសម្ព័ន្ធ២*** រីឯបញ្ជីអ្នកពាក់ព័ន្ធក្នុងការចូលរួមអន្តរាគមន៍បន្ទាន់នានា មាននៅជាគំរូនៅក្នុង ***ឧបសម្ព័ន្ធ៣*** នៃឯកសារនេះផងដែរ។

## សូចនាករស្តង់ដាទី៤- សេវាពិនិត្យសុខភាពដល់អ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សា

ការពិនិត្យសុខភាពអ្នកសិក្សាគួរធ្វើឡើងតាមកាលកំណត់ ដើម្បីដឹងពីស្ថានភាពសុខភាពនិងអាចកាត់បន្ថយនូវគ្រោះថ្នាក់ធ្ងន់ធ្ងរឬពិការភាព ហើយផ្តល់ប្រឹក្សានៃការថែទាំសុខភាព ឬស្វែងរកសេវាព្យាបាលទាន់ពេលវេលាតាមបច្ចេកទេសវេជ្ជសាស្ត្រត្រឹមត្រូវ។ គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សានីមួយៗ ពិសេសមន្ត្រីទទួលបន្ទុកបន្ទប់សុខភាពត្រូវសហការជាមួយមន្ត្រីសុខាភិបាលដើម្បីផ្តល់សេវាពិនិត្យសុខភាពដោយធ្វើឡើងយ៉ាងហោចណាស់១ដងក្នុង១ឆ្នាំសិក្សា ដែលប្រព្រឹត្តទៅជារៀងរាល់ដើមឆ្នាំសិក្សានីមួយៗ។

ការពិនិត្យសុខភាពនៅតាមគ្រឹះស្ថានសិក្សា ត្រូវរួមបញ្ចូលទាំងកញ្ចប់អប្បបរមានៃការពិនិត្យសុខភាព ការបញ្ជូនទៅរកសេវាពិនិត្យព្យាបាល និងការផ្តល់ប្រឹក្សាផងដែរ។

### ១- កញ្ចប់អប្បបរមានៃការពិនិត្យសុខភាព

កញ្ចប់អប្បបរមានៃការពិនិត្យសុខភាពនៅតាមគ្រឹះស្ថានសិក្សា គួរត្រូវបានបែងចែកតាមអាយុរបស់អ្នកសិក្សានៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ដូចបរិយាយខាងក្រោម៖

| មត្តេយ្យសិក្សា | បឋមសិក្សា | មធ្យមសិក្សា |
|---|---|---|
| ការគណនាសន្ទស្សន៍ម៉ាស់រាងកាយ (BMI) | ការគណនាសន្ទស្សន៍ម៉ាស់រាងកាយ (BMI) | ការគណនាសន្ទស្សន៍ម៉ាស់រាងកាយ (BMI) |
| គំហើញឆ្វេង/ស្តាំ | គំហើញឆ្វេង/ស្តាំ | គំហើញឆ្វេង/ស្តាំ |
| កម្លាំងឮឆ្វេង/ស្តាំ | កម្លាំងឮឆ្វេង/ស្តាំ | កម្លាំងឮឆ្វេង/ស្តាំ |
| ប្រមុះ មាត់ធ្មេញ បំពង់ក | ប្រមុះ មាត់ធ្មេញ បំពង់ក | ប្រមុះ មាត់ធ្មេញ បំពង់ក |
| ស្បែក ក្រចក សក់ | ស្បែក ក្រចក សក់ | ស្បែក ក្រចក សក់ |
| អវៈយវៈ | អវៈយវៈ | អវៈយវៈ |
| ឆ្អឹងខ្នង | ឆ្អឹងខ្នង | ឆ្អឹងខ្នង |
| សុខភាពផ្លូវចិត្ត | សុខភាពផ្លូវចិត្ត | សុខភាពផ្លូវចិត្ត |
| បេះដូង | បេះដូង | បេះដូង |
| សួត | សួត | សួត |

| មត្តេយ្យសិក្សា | បឋមសិក្សា | មធ្យមសិក្សា |
|---|---|---|
| ជំងឺឬរបួសផ្សេងៗ | ជំងឺឬរបួសផ្សេងៗ | ជំងឺឬរបួសផ្សេងៗ |
| ការចាក់វ៉ាក់សាំងបង្ការជំងឺ | ការចាក់វ៉ាក់សាំងបង្ការជំងឺ | ប្រដាប់រំលាយអាហារ |

**កំណត់សម្គាល់៖** *ដោយឡែកបុគ្គលិកអប់រំនៅតាមគ្រឹះស្ថានសិក្សាគួរទៅពិនិត្យសុខភាពនៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យសាធារណៈ ឬឯកជនដែលទទួលសេវារបបសន្តិសុខសង្គម (បសស) យ៉ាងហោចណាស់១ដងក្នុង១ឆ្នាំ។*






## ២- ការបញ្ជូនទៅរកសេវាពិនិត្យព្យាបាល៖

ក- ចំពោះសិស្សមត្តេយ្យនិងបឋមសិក្សាពេលពិនិត្យឃើញមានបញ្ហាសុខភាព មន្ត្រីទទួលបន្ទុកបន្ទប់សុខភាពអាចព្យាបាលបឋម ឬត្រូវផ្តល់ព័ត៌មានដល់គ្រូប្រចាំថ្នាក់និងអ្នកអាណាព្យាបាលទៅរកសេវាព្យាបាលសមស្រប។

ខ- ចំពោះសិស្សមធ្យមសិក្សាពេលពិនិត្យឃើញមាន៖

- បញ្ហាសុខភាពតិចតួចមន្ត្រីទទួលបន្ទុកបន្ទប់សុខភាពអាចផ្តល់ប្រឹក្សាយោបល់ ឬណែនាំឱ្យជួបគ្រូពេទ្យដើម្បីចេញវេជ្ជបញ្ជាព្យាបាល
- បញ្ហាសុខភាពធ្ងន់ធ្ងរ មន្ត្រីទទួលបន្ទុកបន្ទប់សុខភាពត្រូវផ្តល់ព័ត៌មានទៅគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា អ្នកអាណាព្យាបាល និងបញ្ជូនទៅរកសេវាសុខភាពដែលនៅជិតបំផុត។



### ៣- ការផ្តល់ប្រឹក្សា៖

មន្ត្រីទទួលបន្ទុកបន្ទប់សុខភាពនិងមន្ត្រីជំនាញគឺជាអ្នកផ្តល់ប្រឹក្សាដល់អ្នកសិក្សា និងបុគ្គលិកអប់រំក្នុងករណីមានបញ្ហាសុខភាពផ្លូវចិត្ត សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ការបៀតបៀនផ្លូវភេទ ដោយ៖

- ទំនាក់ទំនងជាមួយមិត្តភ័ក្តិ អ្នកអាណាព្យាបាល អ្នកជិតខាង គ្រូទទួលបន្ទុកថ្នាក់ និងសាមីខ្លួន
- រៀបចំយន្តការនៃការផ្តល់ប្រឹក្សា ដោយរៀបចំទីកន្លែង ធ្វើការណាត់ជួបអ្នកសិក្សានិងបុគ្គលិកអប់រំដែលមានបញ្ហាសុខភាពដោយជ្រើសរើសពេលវេលា រក្សាការសម្ងាត់ និងជួយដោះស្រាយបញ្ហាដែលកើតមានឡើង។



## សូចនាករស្តង់ដាទី៥- ការផ្តល់ថ្នាំបង្ការដល់អ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សា

វ៉ាក់សាំងនិងថ្នាំបង្ការផ្សេងទៀត ជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការបង្ការជំងឺនានាដែលអាចបង្ការបាន។ បុគ្គលិកអប់រំ និងអ្នកសិក្សាអាចទៅទទួលវ៉ាក់សាំងនៅតាមមូលដ្ឋានសុខាភិបាលទូទាំងប្រទេស ឬតាមកាលកំណត់នៃការផ្តល់វ៉ាក់សាំងដែលជូនដំណឹងដោយអាជ្ញាធរមានសមត្ថកិច្ចនៅតាមមូលដ្ឋានរបស់ខ្លួន។

គ្រឹះស្ថានសិក្សានីមួយៗចាំបាច់ត្រូវសហការជាមួយមូលដ្ឋានសុខាភិបាល ដែលនៅជិត ក្នុងការជំរុញអ្នកសិក្សាទាំងអស់ឱ្យទទួលយកការផ្តល់ថ្នាំបង្ការជំងឺ (វ៉ាក់សាំង) និងថ្នាំបង្ការផ្សេងៗទៀតឱ្យបានគ្រប់ៗគ្នាស្របតាមកម្មវិធីជាតិផ្តល់ថ្នាំបង្ការនៃក្រសួងសុខាភិបាល ជាពិសេសសិស្សមត្តេយ្យសិក្សា និងបឋមសិក្សា។

កម្មវិធីជាតិផ្តល់ថ្នាំបង្ការបាន និងកំពុងបញ្ចូលវ៉ាក់សាំងថ្មីៗជាបន្តបន្ទាប់រហូតមកដល់ពេលនេះមានវ៉ាក់សាំងចំនួន១២មុខ ដែលបានបញ្ចូលទៅក្នុងសកម្មភាពផ្តល់ថ្នាំបង្ការជាប្រចាំ វ៉ាក់សាំងទាំងនោះរួមមាន៖ វ៉ាក់សាំងបង្ការជំងឺរបេង (BCG) រលាកថ្លើមប្រភេទបេ ក្អកមាន់ ខាន់ស្លាក់ តេតាណូស រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគហ៊ីប (DPT-Hep B-Hib) រលាកសួត-រលាកស្រោមខួរក្បាលដែលបង្កដោយមេរោគភ្នឺម៉ូកូក (PCV13) គ្រុនស្វិតដៃជើងប្រភេទបន្តក់ (OPV) គ្រុនស្វិតដៃជើងប្រភេទចាក់ (IPV) កញ្ជ្រឹល-ស្អូច (MR) និងរលាកខួរក្បាលជេអ៊ី (JE) វ៉ាក់សាំងទាំងនេះមានសារៈសំខាន់ណាស់ក្នុងការបង្ការជំងឺទាំង១២មុខខាងលើ ស្របតាមកម្មវិធីជាតិផ្តល់ថ្នាំបង្ការនៃក្រសួងសុខាភិបាល។

ក្រៅពីនេះ គ្រឹះស្ថានសិក្សាត្រូវចូលរួមអនុវត្តការផ្តល់ថ្នាំបង្ការដទៃទៀតដូចជាថ្នាំទម្លាក់ជង្គរព្រូន ថ្នាំជាតិដែកនិងអាស៊ីហ្វូលីក វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជាដើម តាមកម្មវិធីជាតិដែលមានជាធរមាន។






BCG
HepBbirth dose
OPV
OPV1
OPV2
OPV3
IPV
Hib
DPT-Hep B-Hib 1
PAB
DPT-Hep B-Hib 2
DPT-Hep B-Hib 3
PCV
PCV1
PCV2
PCV3
MR
MR1
MR2
JE
BCG Hep B
OPV 1, DPT-Hep B-Hib 1 PCV1
OPV 2, DPT-Hep B-Hib 2 PCV2
OPV 3, DPT-Hep B-Hib 3, PCV3 IPV
MR1 JE
MR2
Mebendazole


28 kg
26 kg
24 kg
22 kg
20 kg
18 kg
16 kg
14 kg
12 kg
10 kg
8 kg
6 kg
4 kg
2 kg
+3
+2
0
-2
-3
0 1 2 3 4 5 6 7 8 9 10 11 12 14 16 18 20 22 24 26 28 30 32 34 36 38 40 42 44 46 48 50 52 54 56 58 60
Reference: WHO Child Growth Standards, 2006 (z-scores) for boys

## សូចនាករស្តង់ដាទី៦- បណ្តាញទឹកស្អាតសម្រាប់ទទួលទានប្រចាំថ្ងៃ

ទឹកជាសារជាតុដែលមនុស្សគ្រប់រូបត្រូវការចាំបាច់ជារៀងរាល់ថ្ងៃដើម្បីទ្រទ្រង់ជីវិតរស់នៅប្រចាំថ្ងៃ។ ការទទួលទានទឹកមិនត្រឹមតែបំបាត់នូវការស្រេកទឹកទេ តែវាផ្តល់ផលប្រយោជន៍ជាច្រើនដល់សារពាង្គកាយរបស់មនុស្ស។ ទឹកអាចជួយឱ្យអ្នកមានអារម្មណ៍ល្អ ជំរុញឱ្យពោះវៀនមានចលនា កុំឱ្យទល់លាមក បណ្តេញជាតិពុលពីរាងកាយ កុំឱ្យមានបញ្ហាក្លិនមាត់ បង្កើនភាពឃ្លានអាហារ និងជួយទប់ស្កាត់ការឈឺក្បាល។

គ្រឹះស្ថានសិក្សាចាំបាច់ត្រូវមានទឹកស្អាតសម្រាប់ទទួលទានប្រចាំថ្ងៃឱ្យបានគ្រប់គ្រាន់ដើម្បីធានាសុខភាព សុវត្ថិភាព និងសុខុមាលភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំ។

ក្នុងដំណាក់កាលដំបូងៗ គ្រឹះស្ថានសិក្សាអាចចាប់ផ្តើមដោយឱ្យសិស្សយកទឹកទទួលទានពីផ្ទះរបស់ខ្លួន ហើយបន្តិចម្តងៗគ្រឹះស្ថានសិក្សាអាចចាប់ផ្តើមមានធុងទឹកចម្រោះឬទឹកស្អាតបន្ថែមសម្រាប់តម្រូវការប្រចាំថ្ងៃនិងរហូតដល់តម្លើងបណ្តាញទឹកស្អាតសម្រាប់ទទួលទានពេញលេញ។

គ្រឹះស្ថានសិក្សាអាចលើកសំណើតបណ្តាញទឹកស្អាតសម្រាប់ទទួលទាន ឧបករណ៍ស្តុកទឹកស្អាតសម្រាប់ទទួលទាននៅតាមគ្រឹះស្ថានសិក្សាពីឃុំ សង្កាត់ អ្នកផ្គត់ផ្គង់ទឹកឯកជន សប្បុរសជន និងអ្នកអាណាព្យាបាល ដោយផ្តើមពីលទ្ធភាពទទួលបានធុងចម្រោះ ប្រព័ន្ធបន្សុទ្ធទឹកស្អាតឬទឹកសម្រាប់ទទួលទានធុងតូចធំតាមធនធានរបស់គ្រឹះស្ថានសិក្សានីមួយៗ។






## ស្ដង់ដាទី៧- ការអនុវត្តយន្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព

គ្រឹះស្ថានសិក្សាចាំបាច់ត្រូវរៀបចំឱ្យមានយន្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាពដើម្បីធានាសុខភាព សុវត្ថិភាព និងសុខុមាលភាពដល់អ្នកសិក្សា និងបុគ្គលិកអប់រំ។ គ្រឹះស្ថានសិក្សានីមួយៗត្រូវយកចិត្តទុកដាក់បំប៉នសមត្ថភាពដល់មន្ត្រីរបស់ខ្លួន ដើម្បីចូលរួមអនុវត្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភ និងអាហារប្រកបដោយសុខភាព ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ការអនុវត្តយន្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាព ត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធដូចជាម្ចាស់អាហារដ្ឋាន អ្នកលក់ដូរចំណីអាហារ ឬអ្នកផ្គត់ផ្គង់អាហារនៅតាមគ្រឹះស្ថានសិក្សានីមួយៗ។ លើសពីនេះ គ្រឹះស្ថានសិក្សាត្រូវសហការជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធជំនាញដើម្បីត្រួតពិនិត្យតាមដានពីសុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភនៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនជាប់ជាប្រចាំ។




អ្នករៀបចំម្ហូបអាហារ អ្នកចម្អិនអាហារ នៅតាមគ្រឹះស្ថានសិក្សា ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមកូនសោគន្លឹះទាំង៥ សម្រាប់ធ្វើឱ្យចំណីអាហារមានសុវត្ថិភាព។ គ្រឹះស្ថានសិក្សានីមួយៗត្រូវយកចិត្តទុកដាក់សហការជាមួយអ្នកពាក់ព័ន្ធជាពិសេសអ្នកលក់ដូរនិងអ្នកផ្គត់ផ្គង់ចំណីអាហារដើម្បីផ្ដល់អាហារប្រកបដោយសុវត្ថិភាព និងអាហារូបត្ថម្ភដល់អ្នកសិក្សានិងហាមឃាត់ការលក់ដូរចំណីអាហារដែលប៉ះពាល់ដល់សុខភាព ដោយធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។

គ្រឹះស្ថានសិក្សាត្រូវសហការជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធជំនាញដើម្បីត្រួតពិនិត្យ តាមដានពីសុវត្ថិភាពចំណីអាហារ និងរៀបចំឱ្យមានការអប់រំផ្សព្វផ្សាយស្ដីពីសុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាពតាមរយៈការបង្កើតជាវេទិការ យុទ្ធនាការ

ឬបិទផ្សាយដល់បុគ្គលិកអប់រំ អ្នកសិក្សា អ្នកលក់ចំណីអាហារ មាតាបិតា អ្នកអាណាព្យាបាល សហគមន៍ និងអ្នកសិក្សា ព្រមទាំងលើកទឹកចិត្តឱ្យមានការបង្ហាញពីបទពិសោធន៍ល្អៗក្នុងការរៀបចំអាហារប្រកបដោយសុវត្ថិភាពនិងសុខភាព។

ដោយឡែក សម្រាប់គ្រឹះស្ថានសិក្សាដែលអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ត្រូវអនុវត្តតាមគោលការណ៍ណែនាំប្រតិបត្តិស្តីពីកម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានដាក់ចេញ។

ផ្ទុយមកវិញគ្រឹះស្ថានសិក្សាដែលមិនទាន់មានលទ្ធភាពរៀបចំអាហារដ្ឋានឬកន្លែងលក់ដូរចំណីអាហារ ឬផ្ទះបាយសាលារៀន គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូត្រូវណែនាំនិងលើកទឹកចិត្តអ្នកអាណាព្យាបាលឱ្យរៀបចំឬវេចខ្ចប់ចំណីអាហារ ទឹកទទួលទានប្រកបដោយសុវត្ថិភាពនិងសុខុមាលភាពដល់បុត្រធីតារបស់ខ្លួនមុនមកសាលារៀន។ ការទទួលទានអាហារគ្រប់គ្រាន់កំឡុងពេលសិក្សា បានជួយឱ្យអ្នកសិក្សាមានថាមពលគ្រប់គ្រាន់ មានការលូតលាស់ប្រកបដោយសុខភាពល្អទាំងរាងកាយ បញ្ញាស្មារតី និងផ្តោតលើសកម្មភាពរៀនសូត្របានល្អ ដែលអាចនាំឱ្យពួកគេទទួលបានលទ្ធផលសិក្សាកាន់តែប្រសើរ។




កន្លែងទទួលទានចំណីអាហារតាមសាលារៀន




ការទទួលទានចំណីអាហារនៅតាមសាលារៀន

## ស្ទូចនាករស្តង់ដាទី៨- សួនបន្លែនិងសួនជីវៈចម្រុះដើម្បីជំរុញការយល់ដឹងពីអាហារូបត្ថម្ភដែលមានលក្ខណៈចម្រុះ

នៅក្នុងគ្រឹះស្ថានសិក្សាគួរមានសួនបន្លែនិងសួនជីវៈចម្រុះដូចជា រោងបន្លែ ដំណាំផ្សេងៗ ការដាំដើមឈើពហុប្រយោជន៍តាមស្ថានភាពដីដើម្បីទទួលបានចំណេះដឹងបរិស្ថានស្អាត និងបង្ហាញពីភាពចម្រុះនៃប្រភេទបន្លែ ផ្លែឈើសម្រាប់បរិភោគ។

គ្រឹះស្ថានសិក្សាអាចរៀបចំសួនបន្លែតាមលទ្ធភាពផ្អែកលើទីតាំងភូមិសាស្ត្រ រដូវកាលនៃពូជដំណាំចម្រុះវិលជុំរយៈពេលខ្លីដូចជា ត្រកួន ស្ពៃ សណ្តែកកួរ ននោង ត្រឡាចម្ទេស ត្រសក់ ស្ពៃក្តោប ត្រប់ ខាត់ណាដើម ឆៃថាវ ជាដើម ព្រមទាំងអាចពិនិត្យលទ្ធភាពចិញ្ចឹមត្រី ឬសត្វមួយចំនួនតាមបច្ចេកទេសកសិកម្ម។

គ្រឹះស្ថានសិក្សាត្រូវសហការជាមួយមន្ត្រីជំនាញកសិកម្ម ឬអ្នកពាក់ព័ន្ធនៅតាមមូលដ្ឋានរបស់ខ្លួនក្នុងការផ្តល់ប្រឹក្សាបច្ចេកទេសអំពីការដាំដុះ និងការចិញ្ចឹមសត្វស្របតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ ដើម្បីទទួលបានលទ្ធផលខ្ពស់និងមានសុវត្ថិភាពក្នុងការទទួលទាន។ ព័ត៌មានលម្អិតស្តីពីការដាំដុះនិងការចិញ្ចឹមសត្វផ្សេងៗអាចរកបានក្នុងវេទិកាផ្សព្វផ្សាយតាមអនឡាញផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទតាមរយៈគេហទំព័រផ្លូវការដូចខាងក្រោម៖

- របៀបដាំដំណាំ៖ https://bit.ly/3QTwE4T
- របៀបចិញ្ចឹមសត្វ៖ https://bit.ly/3bykfn5
- វារីវប្បកម្ម៖ https://bit.ly/3OPuAJI។



## សូចនាករស្តង់ដាទី៩- បណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ

គ្រឹះស្ថានសិក្សាចាំបាច់ត្រូវមានប្រព័ន្ធទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃគ្រប់គ្រាន់ដើម្បីជានាសុខភាព សុវត្ថិភាព និងសុខុមាលភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំ។

គ្រឹះស្ថានសិក្សាអាចពិនិត្យលទ្ធភាពតបណ្តាញទឹកស្អាតពីរដ្ឋាករទឹកឬពីបណ្តាញផ្គត់ផ្គង់ទឹកស្អាតរបស់ឯកជននៅតាមសហគមន៍ ឬពីប្រភពផ្សេងទៀតដែលបានកែលម្អដូចជា អណ្តូងស្នប់ អាងស្តុកទឹកភ្លៀង ទឹកទន្លេ ស្ទឹង។ល។

គ្រឹះស្ថានសិក្សាអាចលើកសំណើតបណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនៅតាម៖

- អាជ្ញាធរឃុំ សង្កាត់ អ្នកផ្គត់ផ្គង់ទឹកឯកជន សប្បុរសជន ដៃគូអភិវឌ្ឍ ឬតាមធនធានរបស់គ្រឹះស្ថានសិក្សានីមួយៗ
- ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តាមរយៈកញ្ចប់ថវិកាជាតិ។





## សូចនាករស្តង់ដាទី១០- បរិក្ខារលាងសម្អាតដៃដោយមានទឹកស្អាតនិងសាប៊ូ សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ

បរិក្ខារលាងសម្អាតដៃជាឧបករណ៍ចាំបាច់សម្រាប់អនុវត្តវិធានការអនាម័យផ្ទាល់ខ្លួនជាប្រចាំដែលគ្រឹះស្ថានសិក្សាចាំបាច់ត្រូវរៀបចំតម្លើងតាមសមាមាត្រអ្នកសិក្សា និងបុគ្គលិកអប់រំ ដើម្បីឱ្យពួកគេមានលទ្ធភាពលាងសម្អាតដៃជាប្រចាំ ឬនៅពេលចាំបាច់គ្រប់វេនសិក្សា។

បរិក្ខារលាងសម្អាតដៃត្រូវរៀបចំតម្លើងនៅជិតបង្គន់អនាម័យ ជិតបន្ទប់រៀន ឬក្បែរអាហារដ្ឋាន តាមជម្រើសផ្សេងៗអនុលោមតាមធនធានរបស់គ្រឹះស្ថានសិក្សា។ បរិក្ខារលាងសម្អាតដៃទាំងអស់ ត្រូវមានទឹក សាប៊ូ និងអាចប្រើប្រាស់បានសម្រាប់មនុស្សគ្រប់រូបព្រមទាំងមានភាពស្អាតជាប់ជាប្រចាំ។

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ត្រូវណែនាំដល់លោកគ្រូ អ្នកគ្រូ ឱ្យចាត់តាំងអ្នកសិក្សាធ្វើការត្រួតពិនិត្យនិងសម្អាតបរិក្ខារលាងសម្អាតដៃជាប្រចាំ។

គ្រឹះស្ថានសិក្សាអាចសាងសង់ តម្លើង ឬបំពាក់បរិក្ខារលាងសម្អាតដៃតាមធនធាននិងស្ថានភាពគ្រឹះស្ថានសិក្សារបស់ខ្លួន។ មានជម្រើសជាច្រើនដែលគ្រឹះស្ថានសិក្សាអាចពិចារណាជាគំរូដូចក្នុងតំណភ្ជាប់គេហទំព័រ https://bit.ly/3Oy16AC។









ទម្រង់ផ្សេងៗនៃកន្លែងលាងសម្អាតដៃនៅតាមសាលារៀន




ទម្រង់ផ្សេងៗនៃកន្លែងលាងសម្អាតដៃនៅតាមសាលារៀន

## សូចនាករស្តង់ដាទី១១- បង្គន់អនាម័យ បង្គន់នោមសមស្របតាមតម្រូវការប្រើប្រាស់ប្រកបដោយបរិយាបន្ន ឯកជនភាព សុវត្ថិភាព និងរក្សាភាពស្អាតជាប់ជាប្រចាំ

វត្តមានបង្គន់អនាម័យនិងបង្គន់នោមព្រមទាំងទឹកស្អាតតាមសាលារៀនគ្រប់គ្រាន់នឹងជួយឱ្យសិស្សមានទំលាប់ល្អឈប់បន្ទោបង់ពាសវាលពាសកាល សាលារៀនមានអនាម័យនិងបរិស្ថានស្អាត ទាក់ទាញសិស្សចូលរៀនកាន់តែច្រើននិងទៀងទាត់ លោកគ្រូអ្នកគ្រូរីករាយនឹងឃើញសិស្សមានសុខភាពល្អ។

ការសាងសង់បង្គន់អនាម័យត្រូវធានាថាសិស្សគ្រប់រូបអាចប្រើប្រាស់បាន ពិសេសត្រូវមានជម្រាលសម្រាប់សិស្សពិការកាយសម្បទា។ បង្គន់អនាម័យដែលសាងសង់រួច ត្រូវមានដំណើរការល្អសម្រាប់សិស្សអាចចូលប្រើប្រាស់បានគ្រប់ម៉ោងសិក្សា មានទឹកលាងសម្អាតយកមកពីប្រភពដែលបានកែលម្អគ្រប់គ្រាន់ មានគន្លឹះទ្វារបិទពីក្នុង គ្មានប្រហោងដែលអាចលួចមើលបាន និងមានបែងចែករវាងបង្គន់ស្រីនិងប្រុសដាច់ដោយឡែកពីគ្នា។ សាលារៀនត្រូវមានបម្រុងសំឡីអនាម័យសម្រាប់សិស្សស្រីប្រើប្រាស់ ពេលត្រូវការបន្ទាន់ និងមានធុងសំរាមក្នុងបង្គន់អនាម័យស្រីនីមួយៗ។

ក្នុងការកសាងបង្គន់អនាម័យ គ្រឹះស្ថានសិក្សាអាចអនុវត្តស្របតាមអនុក្រឹត្យលេខ ២៥ នៃស្តង់ដាជាតិសម្រាប់បង្គន់អនាម័យ ដោយគិតពីសមាមាត្ររវាងចំនួនបង្គន់អនាម័យ និងចំនួនសិស្ស ពោលត្រូវមានបង្គន់អនាម័យពីរនិងបង្គន់នោមបីសម្រាប់សិស្សប្រុស ១០០នាក់ និងបង្គន់អនាម័យបី សម្រាប់សិស្សស្រី១០០នាក់។ ដើម្បីអនុវត្តការងារនេះមានប្រសិទ្ធភាព គណៈគ្រប់គ្រងសាលារៀនគួរពិចារណាលើចំណុចដូចតទៅ៖



- ពិភាក្សារវាងគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីរៀបចំសំណើទៅកាន់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ អាជ្ញាធរមូលដ្ឋានឬសហគមន៍ ឬដៃគូអភិវឌ្ឍនានា ដើម្បីស្នើសុំជំនួយគាំទ្រសម្រាប់ការកសាងបង្គន់ អនាម័យនិងបង្គន់នោមថ្មី ឬជួសជុលបង្គន់អនាម័យដែលមានស្រាប់
- រៀបចំបំពាក់ស្លាកស្រី ប្រុស តាមបង្គន់អនាម័យ ហើយត្រូវរៀបចំឱ្យមានទឹកលាងសម្អាតនិងសម្ភារៈអនាម័យសម្រាប់ប្រើប្រាស់ជាប្រចាំ
- រៀបចំដាក់សំឡីអនាម័យសម្រាប់សិស្សស្រីសម្រាប់តម្រូវការបន្ទាន់និងធុងសំរាមសម្រាប់ចោលសំឡីអនាម័យនៅក្នុងបង្គន់អនាម័យស្រីនីមួយៗ
- ណែនាំលោកគ្រូ អ្នកគ្រូឱ្យរៀបចំវេនសម្អាតបង្គន់អនាម័យសម្រាប់សិស្ស និងតាមដានដំណើរការសម្អាតជាប្រចាំ។





## សូចនាករស្តង់ដាទី១២- ការទុកដាក់សំណល់ ការបែងចែកសំរាមត្រឹមត្រូវស្រប តាមលក្ខណៈបច្ចេកទេស

គ្រឹះស្ថានសិក្សាត្រូវរៀបចំការទុកដាក់សំរាមឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ព្រោះបើទុកដាក់មិនបានត្រឹមត្រូវ សំរាមនឹងក្លាយជាប្រភពចម្លងរោគដល់មនុស្សសត្វដែលនៅជុំវិញ។

ដើម្បីអនុវត្តការងារនេះមានប្រសិទ្ធភាព គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវដឹកនាំៈ




- រៀបចំដាក់ធុងសំរាមក្នុងបរិវេណគ្រឹះស្ថានសិក្សា ដោយមានការញែកកាកសំណល់/សំរាមត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដូចជា សំណល់សរីរាង្គ សំណល់ផ្សេងៗ និងសំណល់កែច្នៃ និងធានាថាគ្មានសំរាមនៅក្នុងបរិវេណគ្រឹះស្ថានសិក្សានិងបន្ទប់រៀន
- រៀបចំបង្កើតវេនសម្អាតបរិវេណសាលារៀន បន្ទប់រៀន បង្គន់អនាម័យ និងបរិក្ខារលាងសម្អាតដៃដល់សិស្ស និងតាមដានដំណើរការសម្អាតជាប្រចាំ
- រៀបចំបង្កើតយុទ្ធនាការនានា សំដៅធ្វើឱ្យគ្រឹះស្ថានសិក្សាមានបរិស្ថានស្អាត និងមានសុវត្ថិភាព ដូចជាការដាក់ស្លាកសញ្ញា "កុំបោចលសំរាមក្រៅធុងសំរាម" ឬ "ហាមយកថង់ប្លាស្ទិកឬចានស្នោរចូលក្នុងបរិវេណគ្រឹះស្ថានសិក្សា" ជាដើម
- បើអាចធ្វើបានអាចបែងចែកដាច់ដោយឡែកសំរាមអេឡិចត្រូនិកដូចជា ថ្មពិល ទូរស័ព្ទ ទូរទស្សន៍ កុំព្យូទ័រ ជាដើម។ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអាច ដើម្បីសិក្សាស្វែងយល់បន្ថែមពីការទុកដាក់សំណល់ថ្មពិលឱ្យបានត្រឹមត្រូវរបស់ក្រសួងបរិស្ថានតាមរយៈការស្កេន QR Code។

## សូចនាករស្តង់ដាទី១៣- អនាម័យបរិស្ថានគ្រឹះស្ថានសិក្សាស្អាតនិងមានសុវត្ថិភាព

បរិស្ថានសិក្សាមានភាពចាំបាច់ណាស់ចំពោះអ្នកសិក្សា ដែលគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវយកចិត្តទុកដាក់ជាចម្បង ដោយត្រូវគិតពីសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព ដោយធ្វើយ៉ាងណាធ្វើឱ្យគ្រឹះស្ថានសិក្សាគ្មានកន្លែងដក់ទឹក ភក់ ជ្រាំ គ្មានសំរាម គ្មានសំបុកពីងពាង គ្មានផ្សែងបារី គ្មានការប្រើប្រាស់ផលិតផលប្លាស្ទីក។ល។

ផ្ទុយទៅវិញគ្រឹះស្ថានសិក្សា ត្រូវមានបំពាក់នូវស្លាកសញ្ញាសុវត្ថិភាពផ្សេងៗ មានរបងការពារកន្លែងមានហានិភ័យ មានកន្លែងជួបជុំពេលមានហានិភ័យ អគ្គីភ័យ គ្រោះទឹកជំនន់ មានបរិស្ថានស្អាតជាប់ជាប្រចាំ។

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវដឹកនាំចលនាស្អាតក្នុងចំណោមក្រុមប្រឹក្សាកុមារ យុវជន ពិសេសត្រូវមានយន្តការបោសសម្អាតបរិវេណគ្រឹះស្ថានសិក្សា បន្ទប់រៀន និងកន្លែងផ្សេងៗទៀតនៃគ្រឹះស្ថានសិក្សា ដើម្បីធានាថា បុគ្គលិកអប់រំនិងអ្នកសិក្សាមានសុវត្ថិភាព។






## សូចនាករស្តង់ដាទី១៤- សួនស្មៅ សួនផ្កា ដើមរុក្ខជាតិសម្រាប់លម្អ និងដើមឈើយកម្លប់

ការរៀបចំឱ្យមានសួនច្បារនៅក្នុងបរិវេណគ្រឹះស្ថានសិក្សាចាត់ទុកថា ជាកត្តាមួយសំខាន់ បំផុតនៅក្នុងពេលបច្ចុប្បន្នក៏ដូចជាទៅអនាគត ព្រោះសួនច្បារបានក្លាយទៅជាចំណុចសំខាន់មួយដោយសារជាមុខជាមាត់របស់គ្រឹះស្ថានសិក្សា។ មិនតែប៉ុណ្ណោះវាថែមទាំងជាការបំពេញបន្ថែមដល់ចំណីចក្ខុវិញ្ញាណនិងភាពរីករាយដល់មនុស្សគ្រប់រូបដែលបានចូលមកដល់ទីនេះព្រមទាំងទាក់ទាញសិស្សានុសិស្សរបស់យើងឱ្យចង់មកគ្រឹះស្ថានសិក្សាផងដែរ។ មាន សួនច្បារអាចកាត់បន្ថយភាពតានតឹងចិត្តជួយបន្ធូរអារម្មណ៍នៅក្នុងខួរក្បាល។



ដើម្បីបង្កើតសួនច្បារមួយឱ្យសមស្របតាមគ្រឹះស្ថានសិក្សាលោកគ្រូ អ្នកគ្រូគួរគិតដល់ចំណុចដូចខាងក្រោម៖

- ធ្វើការសិក្សាពីសួនច្បារដែលគ្រឹះស្ថានសិក្សាផ្សេងៗបានធ្វើកន្លងមក ពិសេសគ្រឹះស្ថានសិក្សាដែលទទួលស្គាល់ថាមានបរិស្ថានស្អាត
- សង្កេតមើលទីតាំងរបស់គ្រឹះស្ថានសិក្សាដែលត្រូវរៀបចំសួនច្បារ និងធ្វើការវិភាគដើម្បីកំណត់ថាតើរុក្ខជាតិណាដែលនឹងលូតលាស់ល្អបំផុតសម្រាប់គ្រឹះស្ថានសិក្សារបស់អ្នក

- ពិចារណាបង្កើតជាសួនឈើប្រណិតដូចជា នាងនួន បេង ផ្គង់ ជាដើម ករណីគ្រឹះស្ថានសិក្សាមានដីធំទូលាយ



- ពិចារណាពីការដាក់វត្ថុតុបតែងកុំធ្វើឱ្យវាហួសប្រមាណបើមិនដូច្នេះទេវាធ្វើឱ្យសួនមានសភាពស្អេកស្កះ។



## សូចនាករស្តង់ដាទី១៥- ទីលានអនុវត្តអប់រំកាយនិងកីឡាសមស្រប

ការអប់រំកាយនិងកីឡាជាធាតុសំខាន់នៃការអប់រំពេញមួយជីវិតនៅក្នុងប្រព័ន្ធអប់រំ។ ការអប់រំកាយនិងកីឡាជានាអភិវឌ្ឍនិងរក្សាការពារកម្លាំងកាយ បញ្ញា ស្មារតី និងសីលធម៌របស់មនុស្ស។ ការរៀបចំឱ្យមានបរិស្ថានល្អ ខ្យល់អាកាសបរិសុទ្ធ មានឧទ្យានបៃតង និងទីធ្លាសម្រាប់អនុវត្តអប់រំកាយនិងកីឡា ដើម្បីទ្រទ្រង់សុខភាពនិងសុខុមាលភាពប្រជាជនទាំងផ្លូវកាយទាំងផ្លូវចិត្ត។ គ្រឹះស្ថានសិក្សាជាកន្លែងដែលសមស្របបំផុតសម្រាប់សិស្សានុសិស្សអនុវត្តអប់រំកាយនិងកីឡា ដូច្នេះគ្រឹះស្ថានសិក្សាត្រូវរៀបចំឱ្យមានទីលានសម្រាប់អនុវត្តអប់រំកាយ និងកីឡាដើម្បីឆ្លើយតបទៅតម្រូវការចាំបាច់របស់សិស្សានុសិស្ស និងបុគ្គលិកអប់រំផងដែរ។

ដើម្បីបង្កើតទីលានសម្រាប់អនុវត្តអប់រំកាយ និងកីឡាឱ្យសមស្របតាមគ្រឹះស្ថានសិក្សាលោកគ្រូ អ្នកគ្រូគួរគិតដល់ការរៀបចំក្រុមការងារដែលមានសមាសភាពចូលរួមពីគណៈកម្មការគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ គ្រូអប់រំកាយនិងកីឡា និងអ្នកមានជំនាញផ្នែកកីឡា។ ក្រុមការងារប្រជុំពិនិត្យពីតម្រូវការទីលានសម្រាប់អនុវត្តអប់រំកាយនិងកីឡា ធនធានសាលាដែលមាននិងកៀគរប្រភពធនធានផ្សេងៗទៀតដែលអាចរកបាន។






## សូចនាករស្តង់ដាទី១៦- ទីធ្លា កន្លែងអង្គុយលេង ឬសម្រាកកម្សាន្តសមស្រប

គ្រឹះស្ថានសិក្សាត្រូវរៀបចំកន្លែងអង្គុយលេង ក៏ដូចជារៀបចំទីធ្លាសម្រាប់សម្រាកកម្សាន្តដល់សិស្សានុសិស្សក្រោយពេលសម្រាកពីការសិក្សាដែលប្រកបដោយផាសុកភាព សុវត្ថិភាព។ ដើម្បីរៀបចំកន្លែងអង្គុយលេងឬទីធ្លាសម្រាប់សម្រាកកម្សាន្តគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ គួរគិតចំណុចមួយចំនួនដូចខាងក្រោម៖

- រៀបចំបង់អង្គុយលេងសម្រាប់សិស្ស និងលោកគ្រូអ្នកគ្រូ សម្រាកក្រោយចប់ម៉ោងសិក្សា
- រៀបចំទីធ្លា មានម្លប់ មានអនាម័យ បរិស្ថានស្អាត និងធំទូលាយ
- រៀបចំឧបករណ៍ ល្បែងកម្សាន្តនៅទីធ្លាគ្រឹះស្ថានសិក្សា
- កន្លែងសមាធិ។ល។









## សូចនាករស្តង់ដាទី១៧- ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅតាមគ្រឹះស្ថានសិក្សា

គ្រឹះស្ថានសិក្សាចាំបាច់ត្រូវចាត់តាំងឱ្យមានក្រុមទទួលបន្ទុកសន្តិសុខសណ្តាប់ធ្នាប់របស់គ្រឹះស្ថានសិក្សាផ្ទាល់ ដឹកនាំដោយគណៈគ្រប់គ្រង និងមានសមាសភាពចូលរួមពីអាជ្ញាធរមូលដ្ឋាន កងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាល កងកម្លាំងកងរាជអាវុធហត្ថ ប្រជាការពារមូលដ្ឋាន និងក្រុមយុវជនស្ម័គ្រចិត្ត ដែលមានតួនាទីភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់។

ក្រុមសន្តិសុខនិងសណ្តាប់ធ្នាប់ប្រចាំគ្រឹះស្ថានសិក្សា មានភារកិច្ចរក្សាសន្តិសុខនៅតាមច្រកចេញ-ចូលគ្រឹះស្ថានសិក្សាជាប្រចាំ ដើម្បីត្រួតពិនិត្យនិងផ្តល់ព័ត៌មានពីសកម្មភាពអ្នកចេញ-ចូល។ ក្នុងករណីមានជនសង្ស័យធ្វើសកម្មភាពមិនប្រក្រតីក្នុងបរិវេណគ្រឹះស្ថានសិក្សា ត្រូវរាយការណ៍បន្ទាន់ជូនប្រធានក្រុមសន្តិសុខនិងសណ្តាប់ធ្នាប់ប្រចាំគ្រឹះស្ថានសិក្សា ដើម្បីមានវិធានការឆ្លើយតប។

គ្រឹះស្ថានសិក្សាអាចចាត់តាំងតំណាងក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន ដើម្បីចូលរួមពង្រឹងសន្តិសុខ សណ្តាប់នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន។ ក្រៅពីការងារទាំងនេះ ក្រុមប្រឹក្សាកុមារឬក្រុមប្រឹក្សាយុវជនអាចចូលរួមជួយការងារចរាចរណ៍នៅមុខគ្រឹះស្ថានសិក្សា និងចូលរួមការអប់រំផ្សព្វផ្សាយពីការបង្ការអំពើអនាចារ ការជួញដូរ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ អំពើហិង្សា និងរាយការណ៍ពីសកម្មភាពក្មេងទំនើងជូនសមត្ថកិច្ចបានទាន់ពេលវេលាផងដែរ។






## សូចនាករស្តង់ដារទី១៨- ឧបករណ៍សម្រាប់បង្ការ ការពារ និងអន្តរាគមន៍ពេលមានគ្រោះអាសន្ននៅតាមអគារសិក្សា

គ្រឹះស្ថានសិក្សានឹងចូលរួមអនុវត្តសកម្មភាពសំខាន់ៗ ដើម្បីជំរុញគ្រឹះស្ថានសិក្សាមានសុវត្ថិភាពគ្រប់ជ្រុងជ្រោយ សំដៅបង្កើនបរិយាកាសសិក្សាប្រកបដោយគុណភាព សុវត្ថិភាព សុខុមាលភាព និងមេត្រីភាព ព្រមទាំងកាត់បន្ថយ ហានិភ័យនៃគ្រោះថ្នាក់ទាំងអស់ ជូនបុគ្គលិកអប់រំនិងអ្នកសិក្សា ដូចខាងក្រោម៖

- បំពាក់សម្ភារៈសុវត្ថិភាព ប្រព័ន្ធបញ្ជូនដំណឹងពីគ្រោះធម្មជាតិ គ្រោះមហន្តរាយ និងអគ្គីភ័យ






- បំពាក់បំពង់ពន្លត់អគ្គីភ័យនៅតាមបរិវេណគ្រឹះស្ថានសិក្សា អគារសិក្សា បន្ទប់រៀន
- បំពាក់អំពូលអគ្គីសនី ឬអំពូលសូឡានៅក្នុងបរិវេណគ្រឹះស្ថានសិក្សា តាមអគារសិក្សា និងបន្ទប់រៀន ជាពិសេសបន្ទប់ទឹក ដើម្បីបំភ្លឺ និងមានសោភ័ណភាព ព្រមទាំងមានសុវត្ថិភាព
- អាចពិចារណាបំពាក់ឧបករណ៍ការពាររន្ទះតាមធនធានដែលមាន

- លេខទូរស័ព្ទទាន់ហេតុការណ៍នានា ដើម្បីស្នើកិច្ចអន្តរាគមន៍បន្ទាន់ណាមួយកើតឡើងនៅគ្រឹះស្ថានសិក្សា។









## សូចនាករស្តង់ដាទី១៩- ផែនការបង្រៀននិងកាលវិភាគបង្រៀនមុខវិជ្ជាអប់រំសុខភាពទៅតាមកម្មវិធីលម្អិត និងប្រធានបទសុខភាពសាធារណៈដទៃទៀតតាមការចាំបាច់

មុខវិជ្ជាអប់រំសុខភាព ត្រូវបានកំណត់ជាមុខវិជ្ជាមួយដែលមានចែងក្នុងក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦ - ២០២៥ ដែលក្នុងនោះមាន១ម៉ោងក្នុង១សប្តាហ៍ពីថ្នាក់ទី១ ដល់ទី១២។ មុខវិជ្ជាអប់រំសុខភាពត្រូវបានរៀបចំជាកម្មវិធីសិក្សាលម្អិតនិងសៀវភៅសិក្សាគោលសម្រាប់គ្រូ សិស្ស ចហើយ ដើម្បីឱ្យមុខវិជ្ជានេះយកទៅបង្រៀនបានត្រឹមត្រូវ។












ដូចនេះ គ្រប់គ្រឹះស្ថានសិក្សាទាំងអស់ត្រូវចូលរួមអនុវត្តការនិងរៀបចំផែនការបង្រៀនដូចខាងក្រោមនេះ។

ដើម្បីអនុវត្តការងារនេះមានប្រសិទ្ធភាព គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវៈ

- រៀបចំផែនការបង្រៀនប្រចាំឆ្នាំ ទៅតាមកម្រិតថ្នាក់នីមួយៗៈ
  - ✓ **សម្រាប់បឋមសិក្សាៈ** គណៈគ្រប់គ្រងនិងគ្រូទទួលបន្ទុកថ្នាក់ ត្រូវពិភាក្សាក្នុងការរៀប ចំផែនការប្រចាំឆ្នាំ ដោយបែងចែកទៅតាមសមាសភាគ ជំពូក និងម៉ោងសិក្សា ដែលមាន១ម៉ោងក្នុងមួយសប្ដាហ៍។ ក្រៅពីនេះលោកគ្រូ អ្នកគ្រូអាចបញ្ជ្រាបពីប្រធានបទសុខភាពសាធារណៈថ្មីៗ ដែលទាក់ទងនឹងការអប់រំបង្ការជំងឺឆ្លង មិនឆ្លង និងរាតត្បាតកាចសាហាវផ្សេងៗទៀត ព្រមទាំងការបង្ការគ្រោះថ្នាក់ផ្សេងៗទៀតដែលកើតមានក្នុងសហគមន៍ នៅពេលចាប់ផ្ដើមបង្រៀនថ្មី តាមរយៈម៉ោងបង្រៀនមុខវិជ្ជាផ្សេងទៀត ពេលគោរពទង់ជាតិ ឬសកម្មភាពជាក្រុម។
  - ✓ **សម្រាប់មធ្យមសិក្សាៈ** គណៈគ្រប់គ្រងនិងគ្រូទទួលមុខវិជ្ជាអប់រំសុខភាពត្រូវពិភាក្សា និងរៀបចំផែនការបង្រៀនប្រចាំឆ្នាំដោយបែងចែកទៅតាមសមាសភាគ ជំពូក និងម៉ោងសិក្សា ដែលមាន១ម៉ោងក្នុងមួយសប្ដាហ៍។ ក្រៅពីនេះលោកគ្រូ អ្នកគ្រូបញ្ជ្រាបការងារការអប់រំបង្ការជំងឺឆ្លង មិនឆ្លង ការបង្ការគ្រោះថ្នាក់ផ្សេងៗ ជំងឺឆ្លងរាតត្បាតកាចសាហាវ និងប្រធានបទសុខភាពសាធារណៈដទៃទៀតដែលកើតមានក្នុងសហគមន៍ដោយសហការជាមួយអ្នកពាក់ព័ន្ធ ដូចជា ក្រុមស.ស.យ.ក ក្រុមកាយរិទ្ធ ក្រុមប្រឹក្សាយុវជន និងក្រុមកាកបាទក្រហម។
- រៀបចំកាលវិភាគបង្រៀន១ម៉ោងក្នុងមួយសប្ដាហ៍ៈ
  - ✓ **សម្រាប់បឋមសិក្សាៈ** គ្រូទទួលបន្ទុកថ្នាក់ត្រូវរៀបចំកាលវិភាគបង្រៀនប្រចាំសប្ដាហ៍ ដោយជ្រើសរើសថ្ងៃ និងម៉ោងបង្រៀនទៅតាមផែនការបង្រៀនប្រចាំឆ្នាំ។
  - ✓ **សម្រាប់មធ្យមសិក្សាៈ** គ្រូទទួលបន្ទុកមុខវិជ្ជាអប់រំសុខភាពរៀបចំកាលវិភាគបង្រៀនប្រចាំសប្ដាហ៍ ដោយជ្រើសរើសថ្ងៃ និងម៉ោងតាមកម្រិតថ្នាក់។

## សូចនាករស្តង់ដាទី២០- សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព និងសម្ភារៈ អប់រំផ្សព្វផ្សាយដទៃទៀត

សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព ជាសម្ភារៈឧបទេសចាំបាច់ក្នុងការបង្រៀនមុខវិជ្ជាអប់រំសុខភាព។ ក្រៅពីសៀវភៅសិក្សាគោល គ្រឹះស្ថានសិក្សាអាចប្រើប្រាស់សៀវភៅ ឬឯកសារអប់រំផ្សព្វផ្សាយផ្សេងៗដែលចេញផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីយកមកបង្រៀនសិស្សឱ្យឆ្លើយតបទៅតាមស្ថានភាពសុខភាពរបស់អ្នកសិក្សាទាំងជំងឺឆ្លង ជំងឺមិនឆ្លង ការបង្ការគ្រោះថ្នាក់នានា ការអប់រំបង្ការគ្រឿងញៀនខុសច្បាប់។ល។

ដើម្បីអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវ៖

- បែងចែកសៀវភៅសិក្សាគោលមុខវិជ្ជា អប់រំសុខភាពសម្រាប់គ្រូ និងសិស្សដល់គ្រូមុខវិជ្ជាអប់រំសុខភាពតាមកម្រិតថ្នាក់
- ផលិតសម្ភារៈឧបទេសដោយខ្លួនឯងដើម្បីគាំទ្រសកម្មភាពបង្រៀនតាមខ្លឹមសារមេរៀនដែលបានរៀបចំ
- ស្នើសុំសម្ភារៈឧបទេស និងសម្ភារៈអប់រំ សម្រាប់បង្រៀន និងអប់រំផ្សព្វផ្សាយពីដៃគូផ្សេងៗនៅតាមមូលដ្ឋានរបស់ខ្លួន។







អប់រំសុខភាព
៧


អប់រំសុខភាព
១០

## សូចនាករស្តង់ដាទី២១- គ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាព

ដើម្បីអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវ៖

- គណៈគ្រប់គ្រងបឋមសិក្សា ត្រូវណែនាំ គ្រូទទួលបន្ទុកថ្នាក់បញ្ចូលម៉ោងអប់រំសុខភាពក្នុងផែនការប្រចាំឆ្នាំ និងកាលវិភាគប្រចាំសប្ដាហ៍
- គណៈគ្រប់គ្រងមធ្យមសិក្សា ត្រូវចាត់តាំងគ្រូដែលមានឧបនិស្ស័យ (មុខវិជ្ជាផែនដី គេហវិទ្យា ជីវវិទ្យា ពលរដ្ឋ...) ដើម្បីបង្រៀនមុខវិជ្ជាអប់រំសុខភាព
- ប្រធានក្រុមបច្ចេកទេសត្រូវបញ្ចូលមុខវិជ្ជាអប់រំសុខភាពទៅក្នុងកិច្ចប្រជុំបច្ចេកទេសរបស់ខ្លួនដើម្បីពិភាក្សាពីបញ្ហាប្រឈម បទពិសោធន៍ក្នុងការបង្រៀន។






## សូចនាករស្តង់ដាទី២២- ការអនុវត្តអនាម័យផ្ទាល់ខ្លួន

ការផ្តល់ចំណេះដឹង បំណិន និងឥរិយាបទត្រឹមត្រូវ តាមរយៈមុខវិជ្ជាអប់រំសុខភាព និងប្រធានបទសុខភាពសាធារណៈថ្មីៗ គឺដើម្បីឱ្យសិស្សមានបំរុងប្រយ័ត្នក្នុងការយកចិត្តដាក់ថែទាំ ការពារ និងបង្ការការឆ្លងជំងឺផ្សេងៗ។

ដើម្បីអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពគណៈគ្រប់គ្រងត្រូវ៖

- រៀបចំសកម្មភាពដុសសម្អាតធ្មេញនិងលាងសម្អាតដៃតាមកាលវិភាគ ដោយយកច្រាសដុសធ្មេញ និងថ្នាំដុសធ្មេញមកសាលាជាប្រចាំ ដើម្បីអនុវត្តឱ្យក្លាយជាទម្លាប់ សម្រាប់បឋមសិក្សា
- អប់រំសិស្សឱ្យអនុវត្តសកម្មភាពលាងសម្អាតដៃមុននិងក្រោយចាប់កាន់ចំណីអាហារ និងក្រោយពេលចេញពីបង្គន់
- រៀបចំសកម្មភាពអប់រំកាយនិងកីឡា ទៅតាមកាលវិភាគ ជាប្រចាំ
- អនុវត្តវិធានអនាម័យក្នុងការសម្អាតខ្លួនប្រាណ
- រៀបចំសកម្មភាពនានាដែលទាក់ទងនឹងការថែរក្សាបរិស្ថាន ដោយចេះបែងចែកនិងទុកដាក់សំរាមតាមប្រភេទនីមួយៗឱ្យបានត្រឹមត្រូវ។
- ការគ្រប់គ្រងការមករដូវ (MHM) ការប្រើប្រាស់សំពត់កំណាត់។








## សូចនាករស្តង់ដាទី២៣- ការអនុវត្តបំណិនសង្គ្រោះបឋម

គ្រឹះស្ថានសិក្សាត្រូវបណ្តុះបណ្តាលវិធីសាស្ត្រសង្គ្រោះបឋមដល់លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សា ដោយសហការជាមួយមន្ត្រីសាខាកាកបាទក្រហមកម្ពុជាប្រចាំមូលដ្ឋាន ឬមន្ត្រីសុខាភិបាលដែលនៅជិត ដើម្បីទទួលបានចំណេះដឹងនិងជំនាញសាមញ្ញៗក្នុងការជួយអន្តរាគមន៍សង្គ្រោះបន្ទាន់ពេលមានគ្រោះថ្នាក់កើតឡើងដោយថាហេតុនៅតាមគ្រឹះស្ថានសិក្សា។




មូលដ្ឋានគ្រឹះនៃការសង្គ្រោះជីវិត

BLS : Basic Life Support

ប្រធានបទសង្គ្រោះបឋមចាំបាច់មួយចំនួនដែលគ្រឹះស្ថានសិក្សាចាំបាច់ត្រូវបណ្តុះបណ្តាលដូចជា ការការពារអ្នករងគ្រោះ ការរុំរបួស ការលើកដាក់អ្នករងរបួសបាក់ឆ្អឹង ការសង្គ្រោះពេលស្លាក់ ពេលឈាមច្រមុះ ពេលរលាកភ្លើង ខ្យល់គ ការសង្គ្រោះពេលពស់ចឹកសត្វខាំ ឬទិច ការសង្គ្រោះពេលលង់ទឹក ការសង្គ្រោះពេលឆក់ខ្សែភ្លើង រន្ទះបាញ់ ការសង្គ្រោះ។ល។






ការបណ្ដុះបណ្ដាលពីវិធីសង្គ្រោះបឋមនេះ អាចធ្វើការរំលឹកឡើងវិញជារៀងរាល់ឆ្នាំ ដើម្បីធានាថា ការងារទាំងអស់នេះត្រូវបានត្រៀមទុកជាមុន និងជៀសវាងការភ័យតក់ស្លុត ឬបាត់ម្ចាស់ការពេលហេតុការណ៍ហានិភ័យផ្សេងៗកើតឡើង។ ជាមួយគ្នានេះ គ្រឹះស្ថានសិក្សានីមួយៗ ចាំបាច់មានលេខទំនាក់ទំនងរថយន្តគិលានសង្គ្រោះដែលនៅជិតបំផុត ដើម្បីជួយអន្តរាគមន៍សង្គ្រោះអ្នករងគ្រោះ។














## សូចនាករស្តង់ដាទី២៤- ការអនុវត្តវិធានការបង្ការជំងឺផ្សេងៗ

ការអនុវត្តវិធានការបង្ការជំងឺឆ្លងនិងជំងឺមិនឆ្លង ជាភារកិច្ចរបស់បុគ្គលិកអប់រំនិងអ្នកសិក្សានៅគ្រប់គ្រឹះស្ថានសិក្សា។ ក្នុងកាលៈទេសៈមួយចំនួន គ្រឹះស្ថានសិក្សាចាំបាច់ត្រូវអនុវត្តនូវវិធានការនានាយ៉ាងម៉ឺងម៉ាត់របស់ក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្ការការពារអាយុជីវិត បុគ្គលិកអប់រំនិងអ្នកសិក្សា ដាក់ស្តែងដូចជាការបង្ការការរាតត្បាតនៃជំងឺកូវីដ-១៩ ជាដើម។




ការអនុវត្តវិធានការបង្ការជំងឺត្រូវធ្វើជាប្រចាំនៅតាមគ្រឹះស្ថានសិក្សា តាមរយៈ៖

- ការណែនាំពេលគោរពទង់ជាតិ ឬណែនាំមុនចាប់ផ្តើមការបង្រៀនជាដើម
- ការបិទផ្សាយសេចក្តីណែនាំដែលចេញផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា ឬក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចនៅខាងក្នុង និងខាងក្រៅបរិវេណគ្រឹះស្ថានសិក្សា

- ម៉ោងអប់រំសុខភាពដែលមានរយៈពេល១ម៉ោងក្នុង១សប្តាហ៍ ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែង។

ករណីនៃការរីករាលដាលនៃជំងឺផ្សេងៗដូចជា ផ្តាសាយ គ្រុនឈាម ស្រឡទែន អ៊ុតស្វាយ ជាដើម គ្រឹះស្ថានសិក្សាត្រូវចាំបាច់ណែនាំអនុវត្តវិធានការបង្ការជំងឺទាំងនោះភ្លាមៗដោយសហការជាមួយគណៈកម្មការសុខភាពសិក្សានៃគ្រឹះស្ថានសិក្សា។ ចំពោះអ្នកសិក្សាឬបុគ្គលិកអប់រំដែលកើតជំងឺទាំងនោះ ដាច់ខាតមិនអនុញ្ញាតឱ្យមកបង្រៀនឬរៀនជាដាច់ខាតរហូតដល់ជាសះស្បើយ ដើម្បីបង្ការការឆ្លងដល់អ្នកដទៃ។



*អ្នកកើតជំងឺស្រឡទែនត្រូវសំរាកព្យាបាលឱ្យជាសះស្បើយទើបអនុញ្ញាតឱ្យចូលសាលារៀន*



*ត្រូវលុបបំបាត់ជម្រកមូសឱ្យអស់ដើម្បីបង្ការជំងឺគ្រុនឈាម គ្រុនឈិ*



*អ្នកកើតជំងឺអុតស្វាយត្រូវសំរាកព្យាបាលឱ្យជាសះស្បើយទើបអនុញ្ញាតឱ្យចូលសាលារៀន*
*អ្នកមិនទាន់កើតអុតស្វាយគួរចាក់វ៉ាក់សាំងបង្ការ*

## សូចនាករស្តង់ដាទី២៥- លំហាត់ប្រាណនិងសកម្មភាពរាងកាយ (គួរបញ្ចូលគ្នាជាមួយសូចនាករទីធ្លាហាត់ប្រាណ)

គ្រឹះស្ថានសិក្សាត្រូវរៀបចំឱ្យមានការហាត់ប្រាណជាក្រុមតាមកម្រិតថ្នាក់ ដោយបែងចែកកាលវិភាគច្បាស់លាស់ និងមានគ្រូណែនាំត្រឹមត្រូវ។ ការហាត់ប្រាណអាចចាប់ផ្តើមពីមេរៀនសាមញ្ញដូចមានចែងក្នុងមេរៀននៃម៉ោងអប់រំសុខភាព ឬកម្មវិធីកីឡាស្របតាមការយល់ដឹងនិងការរីកចម្រើនផ្នែករាងកាយរបស់សិស្ស។

ក្នុងដំណាក់កាលដំបូងៗលោកគ្រូ ឬអ្នកគ្រូអាចធ្វើការណែនាំដោយផ្ទាល់ ហើយនៅពេលសិស្សយល់ដឹងនិងអាចអនុវត្តដោយខ្លួនឯងបាន លោកគ្រូ អ្នកគ្រូអាចចាត់តំណាងសិស្សឱ្យដឹកនាំការហាត់ប្រាណនេះដោយពួកគេផ្ទាល់ តាមរយៈការបំបែកគ្នាជាក្រុមៗ ឬធ្វើរួមគ្នាតាមកម្រិតថ្នាក់ក៏បាន។

ការហាត់ប្រាណ ឬលេងកីឡាមិនគ្រាន់តែធ្វើឱ្យកុមារមានសុខភាពល្អប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យកុមារមានការរីកលូតលាស់រាងកាយ លូតកម្ពស់ និងបង្កើនប្រាជ្ញាស្មារតីមាំមួនថែមទៀតផង។






## ស្ដង់ដាទី២៦- យន្តការកៀរគរប្រភពធនធាននិងការគាំទ្រពីដៃគូពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពសិក្សា

សកម្មភាពនៃការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា មិនអាចកើតមានឡើយប្រសិនបើគ្មានការចូលរួមពីភាគីពាក់ព័ន្ធ។ គ្រឹះស្ថានសិក្សាត្រូវការចាំបាច់នូវធនធានពីដៃគូពាក់ព័ន្ធ វិស័យឯកជន សប្បុរសជនសម្រាប់គាំទ្រសកម្មភាពសុខភាពសិក្សាប្រកបដោយនិរន្តរភាពតាមរយៈការបង្កើតជាយន្តការកៀរគរប្រភពធនធានដូចមានជាឧទាហរណ៍ខាងក្រោម៖

- រៀបចំការប្រជុំជាសាធារណៈជាមួយមាតាបិតា សប្បុរសជន វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត តាមពេលវេលាសមស្របដោយប្រាប់ពីតម្រូវការនិងសកម្មភាពការងារសុខភាពសិក្សាដែលគ្រឹះស្ថានសិក្សាត្រូវការប្រចាំឆ្នាំដោយស្នើឱ្យមានការចូលរួមវិភាគទាន
- បង្កើតឱ្យមានការធ្វើបុណ្យផ្កាសាមគ្គីឬហិបសង្គ្រោះដើម្បីយកមថវិកាមកអភិវឌ្ឍគ្រឹះស្ថានសិក្សា
- ចែករំលែកព័ត៌មានពីសុខភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំដល់មាតា បិតា ឬអ្នកពាក់ព័ន្ធដោយរៀបចំឱ្យមានប្រព័ន្ធទំនាក់ទំនងតាមរយៈតេលេហ្វូន ឬបង្កើតក្រុមតេលេក្រាមក្នុងការ ផ្តល់ព័ត៌មានជាប្រចាំថ្ងៃពីស្ថានភាពសុខភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំ ពិសេសក្នុងបរិបទជំងឺឆ្លងរាតត្បាតដូចជាជំងឺកូវីដ-១៩
- ចែករំលែកព័ត៌មានពីការអនុវត្តការងារលើកកម្ពស់សុខភាពសិក្សាដល់មាតាបិតា អ្នកអាណាព្យាបាល ដៃគូអភិវឌ្ឍ ឬសប្បុរសជន ឬវិស័យឯកជនពីស្ថានភាពការអនុវត្តការងារសុខភាពសិក្សាដោយបង្កើត ប្រព័ន្ធទំនាក់ទំនងផ្សេងៗ តាមកាលកំណត់អាចបីខែម្តងឬមួយឆមាសម្តងជាលាយលក្ខណ៍អក្សរ ផ្សព្វផ្សាយជាសាធារណៈ។



## ៦- សូចនាករស្វ័យវាយតម្លៃការលើកកម្ពស់សុខភាពសិក្សា

គ្រឹះស្ថានសិក្សាដែលអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីការលើកកម្ពស់សុខភាពសិក្សា ត្រូវធ្វើស្វ័យវាយតម្លៃស្ថានភាពនៃគ្រឹះស្ថានសិក្សារបស់ខ្លួនជាទៀងទាត់យ៉ាងហោចណាស់១ត្រីមាសម្តង ដើម្បីវាស់ស្ទង់ស្ថានភាពតាមស្តង់ដានីមួយៗ លទ្ធផលនៃស្វ័យវាយតម្លៃ អាចឲ្យគ្រឹះស្ថានសិក្សាមានមូលដ្ឋានច្បាស់លាស់ក្នុងការរៀបចំផែនការកែលម្អនូវចំណុចទាំងឡាយណាដែលមិនទាន់មាន នៅក្នុងសូចនាករនីមួយៗ។

| ល.រ | សូចនាករស្តង់ដាលើកកម្ពស់សុខភាពសិក្សា | មាន | គ្មាន |
|---|---|---|---|
| **១.** | **គណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា** | | |
| ១.១ | គណៈកម្មការសុខភាពសិក្សានៃគ្រឹះស្ថានសិក្សាជាផ្លូវការដោយមានសមាសភាពអ្នកពាក់ព័ន្ធនិងមានកំណត់តួនាទីនិងភារកិច្ចច្បាស់លាស់ | | |
| ១.២ | គណៈកម្មការសុខភាពសិក្សានៃគ្រឹះស្ថានសិក្សាបានដំណើរការតាមភារកិច្ចនិងតួនាទីដែលបានកំណត់ | | |
| **២.** | **ក្រមប្រតិបត្តិស្តីពីសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា** | | |
| ២.១ | ក្រមប្រតិបត្តិស្តីពីសុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាត្រូវបានបង្កើតនិងសម្រេចជាផ្លូវការ | | |
| ២.២ | ក្រមប្រតិបត្តិស្តីពីសុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សា បានផ្សព្វផ្សាយនិងអនុវត្ត | | |
| **៣.** | **បន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា** | | |
| ៣.១ | បន្ទប់សុខភាពនៃគ្រឹះស្ថានសិក្សាបានបង្កើតដោយមានឧបករណ៍និងសម្ភារៈប្រើប្រាស់សមស្រប | | |
| ៣.២ | បន្ទប់សុខភាពនៃគ្រឹះស្ថានសិក្សាបានដំណើរការដោយមានមន្ត្រីទទួលបន្ទុកប្រចាំការរៀងរាល់ម៉ោងសិក្សា | | |
| ៣.៣ | បន្ទប់សុខភាពនៃគ្រឹះស្ថានសិក្សាមានយន្តការគ្រប់គ្រងនិងប្រើប្រាស់ត្រឹមត្រូវច្បាស់លាស់ | | |

| ល.រ | សូចនាករស្តង់ដាលើកកម្ពស់សុខភាពសិក្សា | មាន | គ្មាន |
|---|---|---|---|
| **៤.** | **សេវាពិនិត្យសុខភាពដល់អ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សា** | | |
| ៤.១ | កិច្ចសហការជាមួយអង្គភាពសុខាភិបាលមូលដ្ឋានឬអង្គភាពសុខាភិបាលដទៃទៀតសម្រាប់ការពិនិត្យសុខភាព និងកាយសម្បទាដល់អ្នកសិក្សា | | |
| ៤.២ | អ្នកសិក្សាទទួលបានសេវាពិនិត្យសុខភាពនិងកាយសម្បទាតាមកាលវិភាគប្រចាំឆ្នាំច្បាស់លាស់ពីមន្ត្រីសុខាភិបាល | | |
| **៥.** | **ការផ្តល់ថ្នាំបង្ការដល់អ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សា** | | |
| ៥.១ | អ្នកសិក្សាទទួលបានថ្នាំបង្ការជំងឺផ្សេងៗតាមកម្មវិធីជាតិនៃការផ្តល់ថ្នាំបង្ការរបស់ក្រសួងសុខាភិបាល | | |
| **៦.** | **បណ្តាញទឹកស្អាតសម្រាប់ទទួលទាននិងប្រើប្រាស់ប្រចាំថ្ងៃ** | | |
| ៦.១ | គ្រឹះស្ថានសិក្សាមានបណ្តាញទឹកស្អាតសម្រាប់ទទួលទានដូចជាបណ្តាញទឹកស្អាត ធុងចម្រោះ ឬប្រព័ន្ធបន្សុទ្ធទឹកស្អាត | | |
| ៦.២ | គ្រឹះស្ថានសិក្សាមានទឹកស្អាតសម្រាប់ឱ្យអ្នកសិក្សាទទួលទានរៀងរាល់ម៉ោងសិក្សា | | |
| ៦.៣ | គ្រឹះស្ថានសិក្សាមានបណ្តាញទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរៀងរាល់ម៉ោងសិក្សា | | |
| **៧.** | **យន្តការផ្តល់និងលើកកម្ពស់សុវត្ថិភាពចំណីអាហារនិងអាហារប្រកបដោយសុខភាព** | | |
| ៧.១ | គ្រឹះស្ថានសិក្សាបានរៀបចំអាហារដ្ឋាន កន្លែងផ្តល់អាហារឬកន្លែងលក់ដូរចំណីអាហារប្រកបដោយសុវត្ថិភាពនិងសុខភាព | | |
| ៧.២ | គ្រឹះស្ថានសិក្សាបានអនុវត្តការលើកកម្ពស់សុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភ និងអាហារប្រកបដោយសុខភាព ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា | | |
| ៧.៣ | កិច្ចសហការជាមួយអង្គភាពឬស្ថាប័នពាក់ព័ន្ធក្នុងការលើកកម្ពស់និងត្រួតពិនិត្យចំណីអាហារនិងអាហារូបត្ថម្ភនៅតាមគ្រឹះស្ថានសិក្សា | | |

| ល.រ | សូចនាករស្តង់ដាលើកកម្ពស់សុខភាពសិក្សា | មាន | គ្មាន |
|---|---|---|---|
| ៧.៤ | គ្រឹះស្ថានសិក្សាមានការអប់រំផ្សព្វផ្សាយពីសុវត្ថិភាពចំណីអាហារូបត្ថម្ភ និងអាហារប្រកបដោយសុខភាព | | |
| **៨.** | **សួនបន្លែនិងសួនជីវៈចម្រុះដើម្បីជំរុញការយល់ដឹងពីអាហារូបត្ថម្ភដែលមានលក្ខណៈចម្រុះ** | | |
| ៨.១ | គ្រឹះស្ថានសិក្សាមានសួនបន្លែនិងសួនជីវៈចម្រុះដើម្បីជំរុញការយល់ដឹងពីអាហារូបត្ថម្ភដែលមានលក្ខណៈចម្រុះ | | |
| ៨.២ | កិច្ចសហការជាមួយអ្នកជំនាញកសិកម្មក្នុងការរៀបចំសួនបន្លែនិងសួនជីវៈចម្រុះដើម្បីជំរុញការយល់ដឹងពីអាហារូបត្ថម្ភដែលមានលក្ខណៈចម្រុះ | | |
| **៩.** | **កន្លែងលាងសម្អាតដៃនិងដុសសម្អាតធ្មេញ ដោយមានទឹកស្អាតនិងសាប៊ូសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ** | | |
| ៩.១ | គ្រឹះស្ថានសិក្សាបានរៀបចំកន្លែងលាងសម្អាតដៃដោយមានទឹកស្អាតនិងសាប៊ូសម្រាប់អ្នកសិក្សានិងបុគ្គលិកអប់រំទាំងអស់ប្រើប្រាស់ជាប្រចាំ | | |
| ៩.២ | អ្នកសិក្សានិងបុគ្គលិកអប់រំបានអនុវត្តការលាងសម្អាតដៃជាមួយទឹកស្អាតនិងសាប៊ូយ៉ាងតិចម្តងតាមវេនសិក្សា | | |
| ៩.៣ | អ្នកសិក្សាបានអនុវត្តការដុសសម្អាតធ្មេញត្រឹមត្រូវជាប្រចាំ | | |
| **១០.** | **បង្គន់អនាម័យ បង្គន់នោមសមស្របតាមតម្រូវការប្រើប្រាស់ ប្រកបដោយបរិយាបន្ន ឯកជនភាព សុវត្ថិភាព និងរក្សាភាពស្អាតជាប់ជាប្រចាំ** | | |
| ១០.១ | គ្រឹះស្ថានសិក្សាបានរៀបចំបង្គន់អនាម័យនិងបង្គន់នោមតាមតម្រូវការប្រើប្រាស់បានចំពោះសិស្សស្រីនិងប្រុសមានលក្ខណៈឯកជនភាព បរិយាបន្ន សុវត្ថិភាព **និងរក្សាភាពស្អាតជាប់ជាប្រចាំ** | | |
| ១០.២ | គ្រឹះស្ថានសិក្សាមានសំឡីអនាម័យជាប្រចាំសម្រាប់សិស្សស្រីប្រើប្រាស់នៅពេលត្រូវការបន្ទាន់ | | |
| ១០.៣ | បង្គន់អនាម័យសិស្សស្រីមានធុងសំរាមសម្រាប់ទុកដាក់សំឡីអនាម័យពេលមករដូវបានត្រឹមត្រូវ | | |

| ល.រ | សូចនាករស្តង់ដារលើកកម្ពស់សុខភាពសិក្សា | មាន | គ្មាន |
|---|---|---|---|
| ១១. | **ការទុកដាក់កាកសំណល់ ការបែងចែកសំរាមត្រឹមត្រូវស្របតាមបច្ចេកទេស** | | |
| ១១.១ | គ្រឹះស្ថានសិក្សាបានរៀបចំទុកដាក់កាកសំណល់និងបែងចែកសំរាមត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស | | |
| ១២. | **អនាម័យបរិស្ថានគ្រឹះស្ថានសិក្សាស្អាតនិងមានសុវត្ថិភាព** | | |
| ១២.១ | បរិស្ថានគ្រឹះស្ថានសិក្សាមានអនាម័យ សោភណភាពនិងសុវត្ថិភាពជាប្រចាំ | | |
| ១៣. | **សួនស្មៅ សួនផ្កា ដើមរុក្ខជាតិសម្រាប់លម្អ និងដើមឈើយកម្លប់** | | |
| ១៣.១ | គ្រឹះស្ថានសិក្សាបានរៀបចំឱ្យមានសួនស្មៅ សួនផ្កា ដើមរុក្ខជាតិសម្រាប់លម្អគ្រប់រដូវកាលរៀនសូត្រ | | |
| ១៣.២ | គ្រឹះស្ថានសិក្សាបានរៀបចំឱ្យមានដើមឈើយកម្លប់គ្រប់រដូវកាលរៀនសូត្រ | | |
| ១៤. | **ទីលានសម្រាប់អនុវត្ត អប់រំកាយនិងកីឡាសមស្រប** | | |
| ១៤.១ | គ្រឹះស្ថានសិក្សាបានរៀបចំទីលានសម្រាប់អនុវត្តអប់រំកាយនិងកីឡាដើម្បីទ្រទ្រង់សុខភាពនិងសុខុមាលភាព | | |
| ១៥. | **ទីធ្លា កន្លែងអង្គុយលេងឬសម្រាកកម្សាន្តសមស្រប** | | |
| ១៥.១ | គ្រឹះស្ថានសិក្សាបានរៀបចំទីធ្លានិងកន្លែងអង្គុយលេងសម្រាប់អ្នកសិក្សានិងបុគ្គលិកអប់រំពេលសម្រាក | | |
| ១៥.២ | គ្រឹះស្ថានសិក្សាបានរៀបចំកន្លែងកម្សាន្តសម្រាប់ អ្នកសិក្សាពេលសម្រាក | | |
| ១៦. | **ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅតាមគ្រឹះស្ថានសិក្សា** | | |
| ១៦.១ | គ្រឹះស្ថានសិក្សាមានរៀបចំក្រុមការងារទទួលបន្ទុកសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពដោយមានបែងចែកតួនាទីនិងភារកិច្ចច្បាស់លាស់ | | |
| ១៦.២ | គ្រឹះស្ថានសិក្សាមានប្រព័ន្ធទំនាក់ទំនងបន្ទាន់អ្នកពាក់ព័ន្ធសម្រាប់ធ្វើអន្តរាគមន៍ក្នុងគ្រឹះស្ថានសិក្សាពេលមានហានិភ័យសុខភាពណាមួយកើតឡើង | | |

| ល.រ | សូចនាករស្តង់ដារលើកកម្ពស់សុខភាពសិក្សា | មាន | គ្មាន |
|---|---|---|---|
| ១៦.៣ | គ្រឹះស្ថានសិក្សាមានផ្សព្វផ្សាយព័ត៌មានសំខាន់ៗអំពីវិធានការបង្ការទប់ស្កាត់ហានិភ័យសុខភាពណាមួយដែលអាចកើតមានឡើងបន្ទាន់ក្នុងគ្រឹះស្ថានសិក្សា | | |
| **១៧.** | **សម្ភារៈ ឧបករណ៍សម្រាប់បង្ការ ការពារ និងអន្តរាគមន៍គ្រោះអាសន្ននៅតាមអគារសិក្សា** | | |
| ១៧.១ | គ្រឹះស្ថានសិក្សាបានរៀបចំសញ្ញាអាសន្នជូនដំណឹងពីគ្រោះធម្មជាតិ គ្រោះមហន្តរាយ និងអគ្គីភ័យ | | |
| ១៧.២ | គ្រឹះស្ថានសិក្សាមានបំពង់ពន្លត់អគ្គីភ័យនៅតាមអគារសិក្សា ឬនៅតាមទីតាំងសំខាន់ៗដទៃទៀតសម្រាប់ប្រើប្រាស់បន្ទាន់ | | |
| ១៧.៣ | បំពង់ទឹកមេសម្រាប់ពន្លត់អគ្គីភ័យនៅតាមបរិវេណគ្រឹះស្ថានសិក្សា អគារសិក្សា បន្ទប់រៀន | | |
| **១៨.** | **ផែនការបង្រៀននិងកាលវិភាគបង្រៀនមុខវិជ្ជាអប់រំសុខភាពទៅតាមកម្មវិធីលម្អិត និងប្រធានបទសុខភាពសាធារណៈដទៃទៀតតាមការចាំបាច់** | | |
| ១៨.១ | គ្រឹះស្ថានសិក្សាមានផែនការបង្រៀនប្រចាំឆ្នាំនិងកាលវិភាគបង្រៀនមុខវិជ្ជាអប់រំសុខភាព១ម៉ោងក្នុងមួយសប្តាហ៍ | | |
| ១៨.២ | ការអប់រំបង្ការជំងឺឆ្លង មិនឆ្លង ការបង្ការគ្រោះថ្នាក់ផ្សេងៗ ជំងឺឆ្លងរាតត្បាតកាចសាហាវ និងប្រធានបទសុខភាពសាធារណៈដទៃទៀតដែលកើតមានក្នុងសហគមន៍ ដោយសហការជាមួយអ្នកពាក់ព័ន្ធ | | |
| **១៩.** | **សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាពនិងសម្ភារៈអប់រំផ្សព្វផ្សាយដទៃទៀត** | | |
| ១៩.១ | គ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពទទួលបានសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព | | |
| ១៩.២ | គ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពបានរៀបចំឬទទួលសម្ភារៈសម្រាប់អប់រំផ្សព្វផ្សាយ | | |
| ១៩.៣ | អ្នកសិក្សាទទួលបានសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាពតាមសមាមាត្រកំណត់ | | |

| ល.រ | សូចនាករស្តង់ដាលើកកម្ពស់សុខភាពសិក្សា | មាន | គ្មាន |
|---|---|---|---|
| **២០.** | **គ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាព** | | |
| ២០.១ | គ្រឹះស្ថានសិក្សាបានរៀបចំឱ្យមានគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពតាមកម្រិតថ្នាក់តាមកាលវិភាគ | | |
| ២០.២ | គណៈគ្រប់គ្រងបានរៀបចំឱ្យមានកិច្ចប្រជុំក្រុមគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពតាមផែនការកំណត់ | | |
| **២១.** | **ការអនុវត្តអនាម័យផ្ទាល់ខ្លួន** | | |
| ២១.១ | គ្រឹះស្ថានសិក្សា (មត្តេយ្យនិងបឋមសិក្សា) បានអនុវត្តសកម្មភាពដុសសម្អាតធ្មេញនិងលាងសម្អាតដៃជាក្រុម | | |
| ២១.២ | គ្រឹះស្ថានសិក្សាបានអនុវត្តសកម្មភាពលាងសម្អាតដៃ | | |
| ២១.៣ | គ្រឹះស្ថានសិក្សាបានអនុវត្តសកម្មភាពដុសសម្អាតធ្មេញ | | |
| ២១.៤ | គ្រឹះស្ថានសិក្សាបានអនុវត្តការត្រួតពិនិត្យអនាម័យខ្លួនប្រាណជាប្រចាំមុនចូលរៀន | | |
| **២២.** | **ការអនុវត្តបំណិនសង្គ្រោះបឋម** | | |
| ២២.១ | គ្រឹះស្ថានសិក្សាបានសហការជាមួយអ្នកពាក់ព័ន្ធក្នុងការបង្រៀនពីវិធីសាស្ត្រនៃការចៀសចេញមានស្ថានភាពគ្រោះថ្នាក់ | | |
| ២២.២ | គ្រឹះស្ថានសិក្សាបានសហការជាមួយអ្នកពាក់ព័ន្ធក្នុងការផ្តល់នូវបំណិនសង្គ្រោះបឋមដល់គ្រូទទួលបន្ទុកផ្នែកសុខភាព និងអ្នកសិក្សា | | |
| **២៣.** | **ការអនុវត្តវិធានការបង្ការជំងឺផ្សេងៗ** | | |
| ២៣.១ | គ្រឹះស្ថានសិក្សាមានការផ្សព្វផ្សាយពីវិធានការបង្ការជំងឺផ្សេងៗតាមរយៈការបិទផ្សាយសារអប់រំ ផ្ទាំងរូបភាពឬការណែនាំផ្ទាល់ | | |
| ២៣.២ | អ្នកសិក្សាបានអនុវត្តវិធានការក្នុងការបង្ការជំងឺឆ្លង ស្របតាមគោលការណ៍ណែនាំប្រតិបត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា ឬក្រសួងសុខាភិបាល ឬអាជ្ញាធរមូលដ្ឋាន | | |

| ល.រ | សូចនាករស្តង់ដាលើកកម្ពស់សុខភាពសិក្សា | មាន | គ្មាន |
|---|---|---|---|
| **២៤.** | **ការហាត់ប្រាណនិងសកម្មភាពរាងកាយ** | | |
| ២៤.១ | អ្នកសិក្សាបានអនុវត្តការ សកម្មភាពអប់រំកាយ និងកីឡាតាមកាលវិភាគ | | |
| ២៤.២ | គ្រឹះស្ថានសិក្សាបានរៀបចំសកម្មភាពកីឡាផ្សេងៗ | | |
| **២៥.** | **យន្តការកៀរគរប្រភពធនធាននិងការគាំទ្រពីដៃគូពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពសិក្សា** | | |
| ២៥.១ | គ្រឹះស្ថានសិក្សាបានកៀរគរប្រភពធនធាននិងការគាំទ្រពីដៃគូ និងអ្នកពាក់ព័ន្ធក្នុងការលើកកម្ពស់សុខភាពសិក្សា | | |
| ២៥.២ | គ្រឹះស្ថានសិក្សាបានចែករំលែកព័ត៌មានពីការលើកកម្ពស់សុខភាពសិក្សារួមទាំងស្ថានភាពសុខភាពអ្នកសិក្សាដល់អ្នកពាក់ព័ន្ធ | | |

# ៧- ឧបសម្ព័ន្ធ

## ៧.១- ឧបសម្ព័ន្ធ១: អំពីបន្ទប់សុខភាព

បន្ទប់សុខភាពគួររៀបចំនៅជាន់ផ្ទាល់ដីជាច់ដោយឡែក មានទីតាំងសមរម្យ មានទ្វារ បង្អួចធំទូលាយ មានខ្យល់ចេញចូល មានពន្លឺគ្រប់គ្រាន់ ប្រកបដោយផាសុកភាព មេត្រីភាព បរិយាបន្ន និងមានសម្ភារៈប្រើប្រាស់សមស្របនិងសម្ភារៈសង្គ្រោះបឋម។

### ១- សម្ភារៈប្រើប្រាស់ក្នុងបន្ទប់សុខភាព៖

ក្នុងបន្ទប់សុខភាពចាំបាច់ត្រូវមានឧបករណ៍ឬសម្ភារៈមួយចំនួនសម្រាប់មន្ត្រីទទួលបន្ទុកបន្ទប់សុខភាពប្រើប្រាស់ពេលអ្នកសិក្សា ឬបុគ្គលិកអប់រំមកទទួលសេវាសុខភាពដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះសម្ភារៈ | ចំនួន | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | គ្រែ | ២ ឬ ៣ | មានកម្ពស់សមល្មមងាយស្រួលក្នុងការឡើងចុះ និងប្រើប្រាស់ (បើអាចមានលទ្ធភាពគួរជាគ្រែដែលអាចវរឡើងចុះបាន) |
| ២ | ពូក | ២ ឬ ៣ | មានសភាពស្តើងល្មម សម្រាប់ដាក់លើគ្រែ ដើម្បីកុំឱ្យឈឺខ្លួនពេលសម្រាក |
| ៣ | កម្រាលពូក | ២ ឬ ៣ | ត្រូវយកកម្រាលពូកពណ៌ស (បើអាចមានលទ្ធភាពគួររកកម្រាលផ្លាស្ទិកបន្ថែម និងពិនិត្យលទ្ធភាពរកកម្រាលសម្រាប់បម្រុងផ្លាស់ប្តូរបន្ថែម) |
| ៤ | ខ្នើយ | ២ ឬ ៣ | ខ្នើយគួរមានសភាពទន់ ដាក់ស្រោមខ្នើយពណ៌ស និងមិនគួរយកខ្នើយដែលខ្ពស់ទេ និងពិនិត្យលទ្ធភាពរកកម្រាលសម្រាប់បម្រុងផ្លាស់ប្តូរបន្ថែម |
| ៥ | ភួយ | ២ | មានសភាពស្តើងល្មម |
| ៦ | ឡប់ឡែ ឬវាំងនន | ៨ ផ្ទាំង | ជាផ្ទាំងកំណាត់សម្រាប់បិទបាំងចន្លោះគ្រែ |
| ៧ | តុ | ២ | អាចតុឈើ ឬ ដែកមានទំហំ និងកម្ពស់សម |

| ល.រ | ឈ្មោះសម្ភារៈ | ចំនួន | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| | | | ល្មមសម្រាប់គ្រូទទួលបន្ទុកសុខភាពធ្វើការ និងអ្នកផ្តល់ប្រឹក្សា |
| ៨ | កៅអី | ១០ | ធ្វើពីឈើឬដែកសម្រាប់គ្រូទទួលបន្ទុកសុខភាព និងអ្នកពាក់ព័ន្ធប្រើប្រាស់ |
| ៩ | ទូដាក់សម្ភារៈពេទ្យ | ១ | សម្រាប់ទុកដាក់ប្រអប់ និងសម្ភារៈ ការពារជំងឺឆ្លង និងសង្គ្រោះបឋម |
| ១០ | ទូដាក់ឯកសារ | ១ | សម្រាប់ទុកដាក់ឯកសារផ្សេងៗដូចជា ក្រូណូឯកសារ ឬបញ្ជីឈ្មោះអ្នកចូលបន្ទប់ឬសម្ភារៈផ្សេងៗ |
| ១១ | ទូទឹកកក | ១ | សម្រាប់ដាក់សម្ភារៈដែលរក្សាទុកកន្លែងត្រជាក់ |
| ១២ | ធុងទឹកក្តៅ ត្រជាក់ (អគ្គិសនី) | ១ | ជាធុងទឹកដោតខ្សែភ្លើងភ្ជាប់នឹងជញ្ជាំង សម្រាប់គ្រូ សិស្សប្រើប្រាស់ |
| ១៣ | កន្លែងលាងសម្អាតដៃ | ១ | សម្រាប់លាងដៃមុនចូលបន្ទប់សុខភាព |
| ១៤ | កង្ហារ | | អាចដាក់លើពិដាន ឬភ្ជាប់ជញ្ជាំង ឬបញ្ឈរ (ចំនួនតាមស្ថានភាពជាក់ស្តែង) |
| ១៥ | ម៉ាស៊ីនត្រជាក់ | ១ | បើអាចមានលទ្ធភាព |
| ១៦ | ធុងសំរាម | ២ | ធុងសំរាមគួរមានគំរប ហើយចែកចេញជាធុងសំរាមសម្រាប់កាកសំណល់វេជ្ជសាស្រ្ត និងសំរាមកាកសំណល់ផ្សេងៗ |
| ១៧ | ជញ្ជីងមានម៉ែត្រ | ១ | សម្រាប់ថ្លឹងនិងវាស់កម្ពស់ |
| ១៨ | ជញ្ជីងអេឡិចត្រូនិក | ១ | សម្រាប់ថ្លឹងទម្ងន់ |
| ១៩ | ឧបករណ៍វាស់កំដៅ | ១ | សម្រាប់វាស់ស្ទង់កម្តៅមុនឱ្យចូលបន្ទប់សុខភាព |
| ២០ | ឧបករណ៍បាញ់ទឹកអាល់កុល | ១ ឬ ២ | សម្រាប់ប្រើប្រាស់លាងសម្អាតដៃមុនពេលចូលបន្ទប់សុខភាព |
| ២១ | ម៉ាស៊ីនសម្លាប់មេ | ១ | សម្រាប់រម្ងាប់មេរោគលើសម្ភារៈមួយចំនួនដូច |

| ល.រ | ឈ្មោះសម្ភារៈ | ចំនួន | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| | ពោគ (អូតូក្លាវ) | | ជា កន្ត្រៃ ដង្កៀប ថាស... |
| ២២ | ស្លាកបន្ទប់សុខភាព | ១ | ព្យួរនៅលើមាត់ទ្វារបន្ទប់សុខភាព |
| ២៣ | នាឡិកាព្យួរជញ្ជាំង ដែលមានវិនាទី | ១ | សម្រាប់មើលម៉ោងពេល ដើម្បីកំណត់ដឹងពីស្ថានភាពអ្នកចូលប្រើប្រាស់បន្ទប់ |
| ២៤ | ក្រាសនិងកញ្ចក់ | ២ ឬ ៣ | សម្រាប់សិតសក់ |
| ២៥ | កន្ត្រៃកាត់ក្រចក | ៤ | សម្រាប់កាត់ក្រចកពេលចាំបាច់ |
| ២៦ | រូបភាព អប់រំសុខភាព | | សម្រាប់បិទឬដាក់តាំង ឬដាក់លើតុសម្រាប់ការអាន ការមើល...តាមការចាំបាច់ប្រើប្រាស់ |
| ២៧ | ប្រអប់សម្រាប់ដាក់សម្ភារៈសង្គ្រោះបឋម | ១ ឬ ២ | សម្រាប់ប្រើប្រាស់ក្នុងករណីចាំបាច់ |
| ២៨ | កុំព្យូទ័រ | ១ | សម្រាប់ប្រើប្រាស់បញ្ចូលទិន្នន័យ |
| ២៩ | E-chart | ១ | សម្រាប់ពិនិត្យភ្នែក |
| ៣០ | ឧបករណ៍វាស់កម្លាំងព្ | ១ | សម្រាប់វាស់កម្លាំងព្ |

ទំហំបន្ទប់សុខភាពនិងសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងបន្ទប់សុខភាពមានភាពប្រែប្រួល និងបត់បែនទៅតាមស្ថានភាព និងលទ្ធភាពនៃគ្រឹះស្ថានសិក្សានីមួយៗ។





## ២- បញ្ជីសម្ភារៈសម្រាប់ការពារជំងឺឆ្លងនិងសង្គ្រោះបឋម

សម្ភារៈសម្រាប់ការពារជំងឺឆ្លង និងសង្គ្រោះបឋម ជាឧបករណ៍ចាំបាច់ដែលត្រូវមាននៅបន្ទប់សុខភាពសម្រាប់សង្គ្រោះបឋមអ្នកសិក្សា ឬ បុគ្គលិកអប់រំពេលមានហេតុការណ៍គ្រោះថ្នាក់ ឬមានបញ្ហាសុខភាពផ្សេងៗនៅក្នុងគ្រឹះស្ថានសិក្សា។ ខាងក្រោមនេះជាបញ្ជីសម្ភារៈដែលត្រូវប្រើប្រាស់៖

| លរ | ឈ្មោះសម្ភារៈ/ថ្នាំ | ចំនួន | រូបភាព | ផ្សេងៗ |
|---|---|---|---|---|
| 1 | ទឹកអាល់កុល៧៥ % (លីត្រ) | 30 |  | |
| 2 | ទឹកអាល់កុល៩៧% (លីត្រ) | 2 |  | |
| 3 | បង់យឺត(ដុំ) | 2 |  | |
| 4 | បង់រុំរបួស (ដុំ) | 5 | | |
| 5 | Thermometer ឌីជីថល | 1 |  | |

| លរ | ឈ្មោះសម្ភារៈ/ថ្នាំ | ចំនួន | រូបភាព | ផ្សេងៗ |
|---|---|---|---|---|
| 6 | Thermometer បារ៉ែត | 2 |  | |
| 7 | ដង្កៀប ( Pince ) | 2 |  | |
| 8 | Bassin haricot | 2 |  | |
| 9 | ថាស bassin ៤ជ្រុង | 2 |  | |
| 10 | ពិលតូច និងថ្ម | 2 |  | |
| 11 | ដំបៀត ពេទ្យ | 2 |  | |
| 12 | កន្ត្រៃពេទ្យ | 2 |  | |
| 13 | កន្ត្រៃកាត់ក្រចក | 2 |  | |

| លរ | ឈ្មោះសម្ភារៈ/ថ្នាំ | ចំនួន | រូបភាព | ផ្សេងៗ |
|---|---|---|---|---|
| 14 | ម៉ាស់ ពេទ្យ (ប្រអប់) | 10 |   | |
| 15 | របាំងមុខ | 10 |  | |
| 16 | ឧបករណ៍ការពារខ្លួន (កម្រិត១) | 50 |  | សម្រាប់ |
| 17 | ឧបករណ៍ការពារខ្លួន (កម្រិត៣) | 10 |  | សម្រាប់ |
| 18 | ស្រោមដៃ (ប្រអប់) | 2 |  | |
| 19 | បង់ស្អិត 2.5cmx5m (ដុំ) | 5 |   | |
| 20 | បង់បិតរបួស 72x18 mm (ប្រអប់) | 2 | | |

| លរ | ឈ្មោះសម្ភារៈ/ថ្នាំ | ចំនួន | រូបភាព | ផ្សេងៗ |
|---|---|---|---|---|
| 21 | សំឡីត្បារត្រចៀក ( កំប៉ុង ) | 2 |   | |
| 22 | សំឡី ( គីឡូ ) | 2 |   | |
| 23 | សំឡីអនាម័យ ( ឡូ ) | 3 |   | |
| 24 | សំឡីដុំមូល ( ថង់ ) | 2 |  | |
| 25 | កំប្រេសតូច ( កញ្ចប់ ) | 20 |   | |
| 26 | កំប្រេសធំ ( កញ្ចប់ ) | 20 | | |
| 27 | ម៉ែតសំពត់ | 2 |  | |

| លរ | ឈ្មោះសម្ភារៈ/ថ្នាំ | ចំនួន | រូបភាព | ផ្សេងៗ |
|---|---|---|---|---|
| 28 | ប្រេងកូឡាឬប្រេងខ្យល់ | 5 |  | |
| 29 | ប្រដាប់វាស់សម្ពាធឈាម (សម្រាប់មនុស្សពេញ វ័យ) | 2 |  | |
| 30 | ប្រដាប់ស្ដាប់បេះដូង ឬសួត (Stetoscope) | 1 |  | |
| 31 | ប្លោកកៅស៊ូ( ស្អំក្បាល) | 2 |  | |
| 32 | Bethadine ដប500ml | 2 |  | |

| លរ | ឈ្មោះសម្ភារៈ/ថ្នាំ | ចំនួន | រូបភាព | ផ្សេងៗ |
|---|---|---|---|---|
| 33 | ទឹកអុកស៊ីសែន 500ml (ដប) | 2 |  | |
| 34 | Tylenol ឬប៉ារ៉ាសេតាម៉ុល៥០០mg (គ្រាប់) | 50 |  | |
| 35 | ថង់ប្លាស្ទីក ទំហំ២kg (ដុំ) | 1 |  | |
| 36 | ជែលស្អំបញ្ចុះកម្ដៅ (ដុំ) | 5 |  | |
| 37 | រទេះរុញ (អង្គុយ) | 1 |  | |

| លរ | ឈ្មោះសម្ភារៈ/ថ្នាំ | ចំនួន | រូបភាព | ផ្សេងៗ |
|---|---|---|---|---|
| 38 | គ្រែរុញ | 1 |  | |
| 39 | កម្រាលជូតជើង | 2 |  | |
| 40 | បំពង់អុកស៊ីសែន | 1 |  | |
| 41 | ខ្សែបំពង់អុកស៊ីសែន | 5 |  | |
| 42 | ម៉ាស់អុកស៊ីសែន | 5 |  | |
| 43 | ឧបករណ៍តេស្តរហ័ស ( កូវីដ-១៩ ) | 100 |   | |

| លរ | ឈ្មោះសម្ភារៈ/ថ្នាំ | ចំនួន | រូបភាព | ផ្សេងៗ |
|---|---|---|---|---|
| 44 | ម្សៅអូរ៉ាលីត (កញ្ចប់) | 20 |   | |
| 45 | Spasfon (គ្រាប់) | 20 |   | |
| 46 | Tanganil (គ្រាប់) | 20 |   | |
| 47 | Smecta (កញ្ចប់) | 20 |   | |
| 48 | សៀវភៅកត់ត្រាអ្នកប្រើប្រាស់ | 1 |   | |

**កំណត់សម្គាល់៖**

- រក្សាទុកនិងប្រើប្រាស់ឧបករណ៍សម្ភារៈនិងថ្នាំឱ្យបានត្រឹមត្រូវតាមការណែនាំ
- បន្ទាប់ពីការប្រើប្រាស់សម្ភារៈឬថ្នាំរួច សូមបំពេញឈ្មោះអ្នកប្រើប្រាស់សម្រាប់តាមដាន
- កាកសំណល់វេជ្ជសាស្ត្រត្រូវគ្រប់គ្រងទុកដាក់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសនីមួយៗ មុននឹងដុតចោលក្នុងធុងដែក ឬដុតក្នុងរណ្ដៅដី ពិសេសឧបករណ៍តេស្តកូវីដ-១៩
- គ្រឹះស្ថានសិក្សានីមួយៗអាចបំពាក់នូវឧបករណ៍ឬសម្ភារៈនានាបន្ថែមតាមតម្រូវការជាក់ស្តែង និងសមត្ថភាពមន្ត្រីទទួលបន្ទុកសុខភាព។

### ៣- លក្ខខណ្ឌតម្រូវនៃការប្រើប្រាស់បន្ទប់សុខភាព

បន្ទប់សុខភាពជាកន្លែងដែលផ្តល់សេវាពិនិត្យសុខភាពនិងកាយសម្បទា សេវាសង្គ្រោះបឋម សេវាផ្តល់ប្រឹក្សាសុខភាពផ្លូវកាយ ផ្លូវចិត្ត សេវាផ្តល់ថ្នាំបង្ការ ឬថ្នាំព្យាបាលនានាតាមគោលនយោបាយជាតិ ឬកម្មវិធីជាតិផ្តល់ថ្នាំបង្ការនៃក្រសួងសុខាភិបាល និងជាកន្លែងផ្តល់ការអប់រំសុខភាពផងដែរ។ ការប្រើប្រាស់បន្ទប់សុខភាពចាំបាច់ត្រូវមានលក្ខខណ្ឌតម្រូវមួយចំនួនដូចខាងក្រោម៖

១- ត្រូវមានអ្នកទទួលបន្ទុកប្រចាំការក្នុងម៉ោងសិក្សាទៅតាមការចាត់តាំងរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ឬគណៈកម្មការសិក្សាសុខភាពសិក្សា។ គ្រឹះស្ថានសិក្សានីមួយៗអាចស្នើសុំមន្ត្រីក្របខណ្ឌឯកទេសសុខាភិបាល ឬចាត់តាំងមន្ត្រីក្របខណ្ឌ ឬជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាជំនាញសុខាភិបាលសម្រាប់បម្រើការងារនៅបន្ទប់សុខភាព ទៅតាមស្ថានភាពជាក់ស្តែងនៃតម្រូវការ។

២- ត្រូវបើកដំណើរការស្របតាមម៉ោងសិក្សានៃគ្រឹះស្ថានសិក្សានីមួយៗ។

៣- ត្រូវអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់តែអ្នកសិក្សា និងបុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សាដែលមានបញ្ហាសុខភាព ឬតម្រូវការសង្គ្រោះបឋម ឬការពិនិត្យសុខភាពនិងកាយសម្បទា ឬ ការផ្តល់ប្រឹក្សាពីសេវាសុខភាពផ្លូវកាយ ផ្លូវចិត្ត ឬករណីចាំបាច់ដទៃទៀតដែលទាក់ទងនឹងសុខភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំ។

៤- មិនអនុញ្ញាតឱ្យអ្នកសិក្សាប្រើប្រាស់បន្ទប់សុខភាព ក្រៅអំពីគោលបំណងនៃការសង្គ្រោះបឋម ការពិនិត្យសុខភាពនិងកាយសម្បទា ឬការផ្តល់ប្រឹក្សាពីសេវាសុខភាពផ្លូវកាយ ផ្លូវចិត្ត ឬសេវាពាក់ព័ន្ធនឹងសុខភាពសាធារណៈដទៃទៀត។

៥- មិនអនុញ្ញាតឱ្យអ្នកសិក្សាប្រើប្រាស់បន្ទប់សុខភាពលើសពីមួយម៉ោងបានទេ ប្រសិនបើមិនមានករណីចាំបាច់។

៦- ត្រូវបញ្ជូនអ្នកជំងឺទៅមូលដ្ឋានសុខាភិបាលដែលនៅជិត ក្នុងករណីមានជំងឺធ្ងន់ធ្ងរលើសពីសមត្ថភាពដែលបន្ទប់សុខភាពអាចជួយបាន ដើម្បីព្យាបាលបន្ត។

៧- មិនត្រូវរក្សាទុកនិងប្រើប្រាស់ឱសថផ្សេងៗ ប្រសិនបើគ្មានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ឬក្រសួងសុខាភិបាល ឬមិនមានបញ្ជាក់ក្នុងបញ្ជីសម្ភារៈសង្គ្រោះបឋម។

៨- ត្រូវគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ សំរាម និងកាកសំណល់ផ្សេងៗតាមលក្ខណៈបច្ចេកទេសឱ្យបានត្រឹមត្រូវ ពិសេសត្រូវសម្អាតផ្ទៃបន្ទប់ និងសម្ភារៈប្រើប្រាស់តាមក្បួនអនាម័យត្រឹមត្រូវជាប្រចាំ។

## ៤- តួនាទី ភារកិច្ចរបស់គណៈគ្រប់គ្រង និងមន្ត្រីទទួលបន្ទុកបន្ទប់សុខភាព

ដើម្បីឱ្យបន្ទប់សុខភាពបំពេញមុខងារបានត្រឹមត្រូវ និងដំណើរការដោយរលូន គ្រឹះស្ថានសិក្សានីមួយៗត្រូវចាត់តាំងឱ្យមានគណៈគ្រប់គ្រង និងមន្ត្រីទទួលបន្ទុកប្រចាំការតាមម៉ោងកំណត់នៃកម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សា។

គណៈគ្រប់គ្រងនិងមន្ត្រីទទួលបន្ទុកបន្ទប់សុខភាពត្រូវមានតួនាទីនិងភារកិច្ចដូចតទៅ៖

១- ត្រូវរៀបចំចាត់ចែងដំណើរការបន្ទប់សុខភាពរៀងរាល់ម៉ោងសិក្សា។

២- ត្រូវសហការផ្តល់សេវាពិនិត្យសុខភាពនិងកាយសម្បទា សង្គ្រោះបឋម ប្រឹក្សាសុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្តល់ថ្នាំបង្ការ ឬថ្នាំព្យាបាលនានាតាមគោលនយោបាយជាតិ ឬកម្មវិធីជាតិផ្តល់ថ្នាំបង្ការនៃក្រសួងសុខាភិបាល និងសេវាអប់រំសុខភាពផងដែរ។

៣- ត្រូវកត់ត្រាអត្តសញ្ញាណអ្នកមកប្រើប្រាស់បន្ទប់សុខភាព ដូចមានបរិយាយបញ្ជាក់ក្នុង **“ឧបករណ៍ទី ១”** ករណីអ្នកមានបញ្ហាសុខភាពធ្ងន់ធ្ងរ ត្រូវចុះបន្ថែមក្នុង **“ឧបករណ៍ ទី ២”** និងករណីអ្នកមានរបួសធ្ងន់ធ្ងរ ត្រូវចុះបន្ថែមក្នុង **“ឧបករណ៍ទី ៣”** ។

៤- ត្រូវផ្តល់ព័ត៌មានបន្ទាន់ដល់អ្នកអាណាព្យាបាលពីស្ថានភាពជំងឺរបស់អ្នកសិក្សា ឬបុគ្គលិកអប់រំ ក្នុងលក្ខខណ្ឌតម្រូវមកទទួលទៅព្យាបាលបន្តនៅផ្ទះ ឬទទួលការឯកភាពមុននឹងបញ្ជូនអ្នកជំងឺទៅព្យាបាលនៅមន្ទីរពេទ្យ។

៥- ត្រូវបញ្ជូនព័ត៌មានដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ដើម្បីធ្វើការសម្រេចចិត្តបញ្ជូនអ្នកជំងឺទៅព្យាបាលបន្តនៅមូលដ្ឋានសុខាភិបាលសាធារណៈដែលនៅជិត ក្នុងករណីមិនអាចទាក់ទងទៅអ្នកអាណាព្យាបាលបាន។

៦- ត្រូវធ្វើរបាយការណ៍សរុបលទ្ធផលការប្រើប្រាស់បន្ទប់សុខភាពរៀងរាល់ដំណាច់ខែ ដូចមានគំរូជូនភ្ជាប់ក្នុង**“ឧបករណ៍ទី ៤”**ជូនគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា និងគណៈកម្មការ សុខភាពសិក្សាគ្រឹះស្ថានសិក្សា និងត្រូវធ្វើ

របាយការណ៍ប្រចាំឆមាសមកក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានសុខភាពសិក្សា)។

៧- ត្រូវគ្រប់គ្រងនិងប្រើប្រាស់សម្ភារៈនៅក្នុងបន្ទប់សុខភាពឱ្យចំគោលដៅដោយមានរបាយការណ៍ប្រើប្រាស់ដូចមានគំរូជូនភ្ជាប់ក្នុង **"ឧបករណ៍ទី ៥"** និងត្រូវជូនដំណឹងដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាដើម្បីបំពេញបន្ថែមសម្ភារៈប្រើប្រាស់ដែលត្រូវការ។

៨- ត្រូវសហការរៀបចំនិងចូលរួមអប់រំផ្សព្វផ្សាយស្តីពីការលើកកម្ពស់សុខភាព សុវត្ថិភាព និងបរិស្ថានស្អាតដល់អ្នកសិក្សា។

៩- ត្រូវស្នើសុំកិច្ចសហការអន្តរាគមន៍បន្ទាន់ ពីអ្នកពាក់ព័ន្ធក្នុងករណីមានបញ្ហាសុខភាពធ្ងន់ធ្ងរ ប្រធានសក្តិ អសន្តិសុខកើតឡើង ហើយគ្រឹះស្ថានសិក្សាមិនអាចដោះស្រាយបាន ដោយរៀបចំជាបញ្ជីឈ្មោះស្ថាប័ន និងលេខទំនាក់ទំនងដូចមានចែងក្នុងចំណុច "VII"។

១០- ត្រូវជូនព័ត៌មានជាសញ្ញាទាន់ហេតុការណ៍ដោយបន្លឺជាសម្លេងជួង កណ្ដឹង ស៊ីរ៉ែន ឬឧបករណ៍បំពងសម្លេងក្នុងគោលបំណងឱ្យមានការប្រុងប្រយ័ត្ន ឬបញ្ចៀសហានិភ័យដែលអាចកើតឡើងជាយថាហេតុ។

១១- ត្រូវរក្សាឯកជនភាព និងរក្សាការសម្ងាត់នូវរាល់ព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពសុខភាពរបស់អ្នកមកទទួលសេវានៅបន្ទប់សុខភាព ព្រមទាំងត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈ។

## ៥- ការងារប្រចាំថ្ងៃសម្រាប់មន្ត្រីទទួលបន្ទុកបន្ទប់សុខភាព

ដើម្បីឱ្យអ្នកសិក្សានិងបុគ្គលិកអប់រំដែលមានបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តមកទទួលសេវានៅបន្ទប់សុខភាពបានទាន់ពេលវេលា តាមតម្រូវការប្រកបដោយផាសុកភាព មេត្រីភាព និងមានទំនុកចិត្ត មន្ត្រីទទួលបន្ទុកបន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សា ត្រូវអនុវត្តការងារប្រចាំថ្ងៃដូចខាងក្រោម៖

១- រៀបចំដំណើរការក្នុងបន្ទប់សុខភាពរៀងរាល់ម៉ោងសិក្សា៖

- បើកដំណើរការបន្ទប់សុខភាព
- សម្អាតបន្ទប់សុខភាពនិងសម្ភារៈប្រើប្រាស់
- ពិនិត្យឧបករណ៍និងសម្ភារៈប្រើប្រាស់

- ទុកដាក់ឧបករណ៍ ឬសម្ភារៈដែលប្រើប្រាស់រួចឱ្យមានរបៀបរៀបរយនិងសណ្ដាប់ធ្នាប់ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

២- រាយការណ៍ប្រចាំថ្ងៃដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាពី៖
- ស្ថិតិនៃអ្នកប្រើប្រាស់បន្ទប់សុខភាព រួមទាំងជំងឺធ្ងន់ធ្ងរ របួសធ្ងន់ធ្ងរ
- ស្ថានភាពបន្ទប់សុខភាពនិងសម្ភារៈប្រើប្រាស់។

៣- បំពេញតួនាទីជា៖
- អ្នកសង្គ្រោះបឋម
- អ្នកផ្ដល់ការអប់រំសុខភាព
- អ្នកផ្ដល់ប្រឹក្សាណែនាំអំពីបញ្ហាសុខភាព
- អ្នកណែនាំពីសេវាសុខាភិបាលផ្សេងៗសម្រាប់តាមដានការថែទាំឬព្យាបាលបន្ត។

៤- បំពេញទម្រង់ឯកសារការងារផ្សេងៗដូចមានចែងក្នុងតារាងឧបករណ៍គំរូ៖
- ឧបករណ៍ទី១ ទី២ និងទី៣ សម្រាប់អ្នកប្រើប្រាស់បន្ទប់សុខភាព
- ឧបករណ៍ទី៤ សម្រាប់របាយការណ៍អ្នកប្រើប្រាស់បន្ទប់សុខភាពប្រចាំខែ
- ឧបករណ៍ទី៥ សម្រាប់របាយការណ៍ស្ដីពីការប្រើប្រាស់សម្ភារៈក្នុងបន្ទប់សុខភាពប្រចាំខែ ដោយបូកសរុបសម្ភារៈដែលបានប្រើប្រចាំថ្ងៃ។

## ៦- វិធានការបង្ការជំងឺកូវីដ-១៩ ជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

ក្នុងករណីមានការឆ្លងរាតត្បាតជំងឺកូវីដ-១៩ ជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត គណៈគ្រប់គ្រងនិងមន្ត្រីទទួលបន្ទុកបន្ទប់សុខភាពនៅតាមគ្រឹះស្ថានសិក្សាត្រូវ៖

- ចូលរួមអនុវត្តឱ្យបានខ្ជាប់ខ្ជួននិងម៉ឺងម៉ាត់នូវគោលការណ៍ណែនាំ សារាចរណែនាំ លក្ខខណ្ឌតម្រូវ ឬគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) របស់រាជរដ្ឋាភិបាល ឬក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា
- ចូលរួមសហការលើកវិធានការចាំបាច់នានាដើម្បីធានាសុវត្ថិភាពនិងសុខភាពដល់អ្នកសិក្សានិងបុគ្គលិកអប់រំនៅតាមគ្រឹះស្ថានសិក្សា

- ស្ថិតនៅចំពោះមុខនៃការឆ្លងរាតត្បាតជំងឺកូវីដ-១៩ គណៈគ្រប់គ្រងនិងមន្ត្រីទទួលបន្ទុកបន្ទប់សុខភាពត្រូវអនុវត្តនូវវិធានការដូចជា៖
  - ✓ ត្រូវពាក់ម៉ាស់ និងរបាំងមុខ រក្សាគម្លាតសុវត្ថិភាពបុគ្គល និងលាងសម្អាតដៃឱ្យបានញឹកញាប់រាល់ពេលបំពេញការងារ
  - ✓ ត្រូវរៀបចំឱ្យមានឧបករណ៍តេស្តរហ័សនិងឧបករណ៍ការពារខ្លួន (PPE = Personal Protective Equipment) ដូចជា អាវសុវត្ថិភាព ឬអាវបំពង់ ម៉ាស់ មួក របាំងមុខ ស្រោមដៃ ស្រោមជើង ព្រមទាំងឧបករណ៍វាស់កម្ដៅ និងសម្ភារៈអនាម័យដូចជាអាល់កុល ឬអាល់កុលជែល សាប៊ូ ទឹកស្អាត សម្រាប់ប្រើប្រាស់នៅបន្ទប់សុខភាព
  - ✓ ត្រូវធ្វើតេស្តរហ័សចំពោះអ្នកសង្ស័យមុនអនុញ្ញាតឱ្យប្រើប្រាស់បន្ទប់សុខភាព។

## ៧.២- ឧបសម្ព័ន្ធ២ : ឯកសារចាំបាច់សម្រាប់ប្រើប្រាស់នៅបន្ទប់សុខភាព

### ១- បញ្ជីឈ្មោះអ្នកប្រើប្រាស់បន្ទប់សុខភាព (ឧបករណ៍ទី១)

ខែ.......................... ឆ្នាំ......................

| ល.រ | ឈ្មោះ | ភេទ | ឆ្នាំ/ថ្នាក់ | ប្រភេទបញ្ហា | កាលបរិច្ឆេទ | ដំណោះស្រាយ & សម្ភារៈដែលប្រើប្រាស់ | បន្ទាប់ពីការព្យាបាលរួច |
|---|---|---|---|---|---|---|---|
| ១ | ស៊ី ថា | ស | ៣ ក | វិលមុខ | ១២ មិថុនា ២០២១ | សម្រាកដោយប្រើប្រេងខ្យល់ ឬប្រេងកូឡា | ទៅថ្នាក់រៀនវិញ |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ..... | | | | | | | |
| ..... | | | | | | | |
| ..... | | | | | | | |

ឧបករណ៍ទី១ខាងលើនេះ អាចរៀបចំជាសៀវភៅ ឬបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីរក្សាទិន្នន័យសម្រាប់តាមដាន និងធ្វើជាមូលដ្ឋានក្នុងការធ្វើរបាយការណ៍។

## ២- ទម្រង់អ្នកមានបញ្ហាសុខភាពធ្ងន់ធ្ងរ ( ឧបករណ៍ទី២ )

កាលបរិច្ឆេទ: ................/............................../..................

| | | |
|---|---|---|
| ឈ្មោះ.......................................................<br>ភេទ.............<br>ឆ្នាំទី......... មុ ខវិជ្ជា............................. | | ម៉ោងមកដល់...........................<br>សីតុណ្ហភាពប៉ុន្មាន ? .......... ℃ |
| រោគសញ្ញា | ① ឈឺក្បាល ② ឈឺពោះ ③ ទន់ខ្លួន ④ ក្អួតចង្អោរ<br>⑤ មិនស្រួលខ្លួន ⑥ ផ្សេងៗ (..........................) | |
| កម្ពស់............ស.ម<br>ទម្ងន់............គ.ក្រ | សម្ពាធឈាម...........................................................<br>ជីពចរ.......................................................................... | |
| ការចាប់ផ្តើមនៃរោគសញ្ញាខាងលើ | ① តាំងពីម្សិលមិញ ② តាំងពីព្រឹក<br>③ ចាប់តាំងពីម៉ោង ..................................................<br>④ ផ្សេងៗ (..........................................) | |
| ពេលចូលដំណេក | ម៉ោងចូលគេង ...............<br>ម៉ោងក្រោកពីគេង .......... | រយៈពេលគេង...............ម៉ោង |
| អារម្មណ៍នៅពេលភ្ញាក់ពីដំណេក | ① មានអារម្មណ៍ស្រស់ស្រាយ ② នៅងងុយគេង<br>③ ខ្សោយ ④ ឈឺក្បាល ⑤ ឈឺពោះ ⑥ មិនចង់ភ្ញាក់ពីគេង<br>⑦ ផ្សេងៗ (..............................................) | |
| តើបរិភោគអាហារពេលព្រឹកហើយឬនៅ ? | ① រួចហើយ ② មិនទាន់បរិភោគ<br>ហេតុផល ☐ មិនឃ្លាន ☐ គ្មានពេល ☐ មិនបរិភោគអាហារពេលព្រឹក | |
| ការបន្ទោបង់នៅពេលព្រឹក | ① រួចហើយ (ធម្មតា រឹង រាក) ② មិនទាន់ | |
| ហេតុផលនៃស្ថានភាពមិនស្រួលខ្លួន | ① នឿយហត់ ② ចូលគេងយប់ជ្រៅពេក ③ ចង់ផ្តាសាយ<br>④ ទល់លាមក ⑤ រាក ⑥ មានរឿងមិនសប្បាយចិត្ត<br>⑦ មិនដឹង ⑧ ផ្សេងៗ................. | |

| | |
|---|---|
| តើមានអារម្មណ៍មិនស្រួលដែរឬទេ ? | ① មាន ( តើមិនសូវស្រួលកន្លែងណា ?.......................... )<br>② គ្មាន |
| តើអ្នកចង់ធ្វើអ្វីនៅពេលនេះ ? | ① ត្រលប់ទៅថ្នាក់រៀនវិញ ② ចង់សម្រាកនៅបន្ទប់សុខភាព<br>③ ចង់ពិគ្រោះយោបល់ ④ ចង់ត្រលប់ទៅផ្ទះវិញ<br>⑤ ខ្ញុំមិនដឹង |

| | | |
|---|---|---|
| **សេចក្តីសន្និដ្ឋាន** | ① ត្រឡប់ទៅថ្នាក់រៀនវិញ<br>② សម្រាកនៅបន្ទប់សុខភាព → ត្រឡប់ទៅថ្នាក់រៀនវិញ<br>③ សម្រាកនៅបន្ទប់សុខភាព → ទាក់ទងអ្នកអាណាព្យាបាល→ ចេញទៅផ្ទះមុនម៉ោង → ម៉ោងទៅផ្ទះ.................... | **<u>វិធីសាស្រ្តដោះស្រាយ</u>** |

## ៣- ទម្រង់អ្នកមានរបួសធ្ងន់ធ្ងរ ( ឧបករណ៍ទី៣ )

កាលបរិច្ឆេទ:.........../................./....................

| | |
|---|---|
| ឈ្មោះ..............................<br>ភេទ............ ឆ្នាំទី...............<br>មុខវិជ្ជា................................. | ម៉ោងមកដល់.....................<br>សីតុណ្ហភាពប៉ុន្មាន ? ....... °C |

| | |
|---|---|
| ប្រភេទនៃគ្រោះថ្នាក់ | ① រលាត់ស្បែក ② មុតជើង ③ បាក់ដៃ<br>④ បាក់ជើង ⑤ បែកក្បាល<br>⑥ ផ្សេងៗ (.........................................) |
| ការពណ៌នាលម្អិតនៃស្ថានភាពរបួស | ...........................................................................<br>........................................................................... |
| មូលហេតុនៃគ្រោះថ្នាក់ | ...........................................................................<br>........................................................................... |
| ពេលវេលានៃគ្រោះថ្នាក់ | ម៉ោង ...................... |
| កម្ពស់..................ស.ម<br>ទម្ងន់........គ.ក្រ | សម្ពាធឈាម..................................................<br>ជីពចរ........................................................ |

| | | |
|---|---|---|
| **សេចក្តីសន្និដ្ឋាន** | ① ត្រឡប់ទៅថ្នាក់រៀនវិញ<br>② បញ្ជូនទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ<br>③ ព្យាបាលនៅបន្ទប់សុខភាព → ត្រឡប់ទៅថ្នាក់រៀនវិញ<br>④ ព្យាបាលនៅបន្ទប់សុខភាព →ទាក់ទងអ្នកអាណាព្យាបាល→ចេញទៅផ្ទះមុន (ម៉ោងទៅផ្ទះ...................) | **វិធីសាស្ត្រដោះស្រាយ** |

## ៤- គំរូរបាយការណ៍អ្នកប្រើប្រាស់បន្ទប់សុខភាពប្រចាំខែ (ឧបករណ៍ទី៤)

ឈ្មោះគ្រឹះស្ថានសិក្សា...................................................

ឆ្នាំសិក្សា.......................................................................

| ល.រ | ប្រភេទបញ្ហា | ចំនួន | ខែនៃឆ្នាំសិក្សា | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | |
| ១ | របួស | សរុប | 10 | 10 | 10 | 10 | 10 | 10 | 10 | 10 | 10 | 10 | 100 |
| | | ស្រី | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 20 |
| ២ | | សរុប | | | | | | | | | | | |
| | | ស្រី | | | | | | | | | | | |
| ៣ | | សរុប | | | | | | | | | | | |
| | | ស្រី | | | | | | | | | | | |
| ៤ | | សរុប | | | | | | | | | | | |
| | | ស្រី | | | | | | | | | | | |
| ៥ | | សរុប | | | | | | | | | | | |
| | | ស្រី | | | | | | | | | | | |
| ... | | សរុប | | | | | | | | | | | |
| | | ស្រី | | | | | | | | | | | |

ថ្ងៃ..............ខែ.................ឆ្នាំ២០២...

**បានឃើញនិងឯកភាព**

ប្រធានគណៈគ្រប់គ្រងបន្ទប់សុខភាព

ឬគ្រឹះស្ថានសិក្សា

**អ្នកធ្វើតារាង**

**សម្គាល់:** *ឧបករណ៍ទី៤ ខាងលើនេះអាចរៀបចំជាតារាង ឬបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីរក្សាទិន្នន័យសម្រាប់តាមដាន និងធ្វើជាមូលដ្ឋានក្នុងការធ្វើរបាយការណ៍។ ដោយឡែកខែ នៃការចាប់ផ្តើមឆ្នាំសិក្សាអាចបត់បែនទៅតាមស្ថានភាពជាក់ស្តែងនៃគ្រឹះស្ថានសិក្សានីមួយៗ។*

## ៥- របាយការណ៍ស្ដីពីការប្រើប្រាស់សម្ភារៈក្នុងបន្ទប់សុខភាពប្រចាំខែ
## (ឧបករណ៍ទី៥)

ឈ្មោះគ្រឹះស្ថានសិក្សា.................................................................

ឆ្នាំសិក្សា...........................................................................

| ល.រ | បរិយាយសម្ភារៈ | ចំនួន | ខែនៃឆ្នាំសិក្សា | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| ១ | សំឡី (គ.ក្រ) | 17 | 1 | 2 | 2 | 1 | 2 | 1 | 2 | 2 | 3 | 1 |
| ២ | | | | | | | | | | | | |
| ៣ | | | | | | | | | | | | |
| ៤ | | | | | | | | | | | | |
| ...... | | | | | | | | | | | | |
| ហត្ថលេខាអ្នកត្រួតពិនិត្យ | | | | | | | | | | | | |

ថ្ងៃ..............ខែ................ឆ្នាំ២០២...

**បានឃើញនិងឯកភាព** **អ្នកធ្វើតារាង**

ប្រធានគណៈគ្រប់គ្រងបន្ទប់សុខភាព

ឬគ្រឹះស្ថានសិក្សា

**សម្គាល់៖**

- *ឧបករណ៍ទី៥ខាងលើនេះ អាចរៀបចំជាតារាង ឬបញ្ចូលក្នុងកុំព្យូទ័រដើម្បីរក្សាទិន្នន័យសម្រាប់តាមដាន និងធ្វើជាមូលដ្ឋានក្នុងការធ្វើរបាយការណ៍។ ដោយឡែកខែនៃការចាប់ផ្ដើមឆ្នាំសិក្សាអាចបត់បែនទៅតាមស្ថានភាពជាក់ស្ដែងនៃគ្រឹះស្ថានសិក្សានីមួយៗ។*
- *មន្ត្រីទទួលបន្ទុកបន្ទប់សុខភាពត្រូវត្រួតពិនិត្យសម្ភារៈម្ដងរួចកត់ត្រាចូលបញ្ជីខាងលើនេះរៀងរាល់ខែ ករណីសម្ភារៈដែលផុតកំណត់ត្រូវស្នើសុំប្ដូរថ្មី*
- *មន្ត្រីទទួលបន្ទុកបន្ទប់សុខភាពត្រូវត្រួតពិនិត្យបញ្ជីសម្ភារៈដែលប្រើប្រាស់រៀងរាល់ខែ និងលើកសំណើជូនគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាដើម្បីបំពេញបន្ថែមតាមតម្រូវការប្រើប្រាស់ជាក់ស្ដែង។*

## ៦- គំរូកំណត់ហេតុនៃការចំណាយផ្សេងៗសម្រាប់ប្រតិបត្តិការបន្ទប់សុខភាព (ឧបករណ៍ទី៦)

| បរិយាយនៃមុខចំណាយ | កាលបរិច្ឆេទចំណាយ | ចំនួនចំណាយ | ឈ្មោះនិងហត្ថលេខាអ្នកទទួលខុសត្រូវ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

ថ្ងៃ...............ខែ.................ឆ្នាំ២០២......

**អ្នកធ្វើតារាង**

**បានឃើញនិងឯកភាព**

ប្រធានគណៈគ្រប់គ្រងបន្ទប់សុខភាព

ឬគ្រឹះស្ថានសិក្សា

## ៧.៣- ឧបសម្ព័ន្ធ៣ : អ្នកពាក់ព័ន្ធសម្រាប់ទាក់ទងបន្ទាន់

ករណីខ្លះអ្នកសិក្សា ឬបុគ្គលិកអប់រំត្រូវការបញ្ជូនទៅរកសេវាព្យាបាលបន្តនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ហេតុនេះនៅបន្ទប់សុខភាពចាំបាច់ត្រូវមានទំនាក់ទំនងជាមួយមូលដ្ឋានសុខាភិបាលដែលនៅកៀកនឹងគ្រឹះស្ថានសិក្សា។ ខាងក្រោមនេះ ជាតារាងគំរូអ្នកពាក់ព័ន្ធ ដែលគ្រឹះស្ថានសិក្សានីមួយៗត្រូវមានដើម្បីងាយស្រួលទាក់ទងពេលត្រូវការជំនួយក្នុងការព្យាបាល ឬថែទាំបន្ត។

| អ្នកពាក់ព័ន្ធ | ឈ្មោះ | លេខទូរស័ព្ទ/អាសយដ្ឋាន |
|---|---|---|
| គ្រូទទួលបន្ទុកបន្ទប់សុខភាព | | |
| មន្ទីរពេទ្យ/មណ្ឌលសុខភាព ដែលនៅក្បែរបំផុតឬមានទំនាក់ទំនងជាមួយគ្រឹះស្ថានសិក្សា | | |
| គ្លីនិក ឬ មន្ទីរសម្រាកព្យាបាលឯកជនដែលមានទំនាក់ទំនងជាមួយគ្រឹះស្ថានសិក្សា | | |
| រថយន្តគិលានសង្គ្រោះ | | ១១៩ |
| ព័ត៌មានសុខាភិបាល | | ១១៥ |
| គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា | | |
| ឱសថស្ថានផ្គត់ផ្គង់សម្ភារៈពេទ្យផ្សេងៗ | | |

**សម្គាល់៖**

- *ចំពោះលេខទំនាក់ទំនងគណៈគ្រប់គ្រង និងមន្ត្រីទទួលបន្ទុកបន្ទប់សុខភាព ចាំបាច់ត្រូវដាក់នៅខាងក្រៅបន្ទប់ ដើម្បីអ្នកប្រើប្រាស់សេវាងាយទាក់ទង*
- *ចំណែកលេខទំនាក់ទំនងអ្នកអាណាព្យាបាល អាចបែងចែកតាមបន្ទប់រៀន/ថ្នាក់រៀន ដើម្បីងាយស្រួលទាក់ទងពេលមានតម្រូវការបន្ទាន់នានា*
- *គ្រឹះស្ថានសិក្សានីមួយៗអាចបន្ថែមលេខទំនាក់ទំនងអ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។*

ពិចារណាបន្ថែមឧបសម្ព័ន្ធ ផែនការបង្រៀន កាលវិភាគបង្រៀន ការទម្លាក់ដង្កូវព្រូន (សំណើនិងរបាយការណ៍)

## ៨- ឯកសារយោង


១- គោលនយោបាយជាតិស្តីពីសុខភាពសិក្សា

២- Making every school a healthy-promoting school, **Global standards and indicators,** World Health Organization and UNESCO, Education 2030

៣- Making every school a healthy-promoting school, **Implemtion guidance**, World Health Organization and UNESCO, Education 2030

៤- WHO guideline on school health services, World Health Organization and UNESCO

៥- Making every school a healthy-promoting school, **Country case studies**, World Health Organization and UNESCO, Education 2030

៦- គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

៧- សេចក្តីណែនាំលេខ ១៨ អយក.សណន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការពង្រឹងវិធានការអនុវត្ត ការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន

៨- គោលការណ៍ណែនាំស្តីពីសាលាមេត្រីបរិស្ថាននៅកម្ពុជា

៩- ឯកសារណែនាំស្តីពីបុគ្គលិកអប់រំនិងការិយាល័យស្អាតនិងមានអនាម័យ